# សេចក្តីណែនាំជាគោលនយោបាយ ស្តីអំពីការសំគាល់ជនរងគ្រោះពីការជួញដូរ




## សេចក្តីណែនាំដំបូងសម្រាប់ អ្នកសាងគោលនយោបាយ និងអ្នកអនុវត្ត




នីតិវិធីក្រុងបាលីស្តីអំពីការរត់ពន្ធមនុស្ស ការជួញដូរមនុស្ស ហើយនិង
ឧក្រិដ្ឋកម្មឆ្លងដែនពាក់ព័ន្ធ(នីតិវិធីក្រុងបាលី) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ
២០០២ និងជាកម្មវិធីពិគ្រោះយោបល់ក្នុងតំបន់ដែលធ្វើឡើងដោយការ
ស្ម័គ្រចិត្តនិងមិនមានចំណងហើយនិងមានរដ្ឋាភិបាលអូស្ត្រាលីនិងឥណ្ឌូ
ណេស៊ីជាសហប្រធាន និងប្រទេសនិងអង្គការ៤៥ជាសមាជិក។
ចំពោះសំនួរទាំងឡាយទាក់ទងនឹងសេចក្តីណែនាំជាគោលនយោបាយនេះ
សូមបញ្ជូនទៅ ការិយាល័យជំនួយការប្រចាំដំបន់ (RSO) សម្រាប់នីតិវិធី
ក្រុងបាលី តាមអ៊ីម៉េល info@rso.baliprocess.net
គេហទំព័ររបស់ RSO:
http://www.baliprocess.net/regional-support-office
បោះពុម្ពនៅខែឧសភា ឆ្នាំ ២០១៥

# អ្នករួមចំណែកចងក្រង

សេចក្តីណែនាំជាគោលនយោបាយនេះ បានសាងឡើងដោយសមាជិកនៃនីតិវិធីក្រុងបាលី គាំទ្រដោយការិយាល័យជំនួយការប្រចាំដំបន់ ហើយនិងដឹកនាំដោយគណៈកម្មាធិការព្រាងសេចក្តីណែនាំជាគោលនយោបាយនៃនីតិវិធីក្រុងបាលី មានសមាជិកដូចតទៅ៖

---

**ឡាលូ មុហាម៉ាត់ អ៊ីកបាល់** ( Lalu Muhamad Iqbal )
នាយកស្តីទី នៃនាយកដ្ឋានការពារប្រជាពលរដ្ឋឥណ្ឌូនេស៊ីនិងនីតិបុគ្គល
ក្រសួងការបរទេស ប្រទេសឥណ្ឌូនេស៊ី ( សហប្រធាន )

---

**ចណាធិន ម៉ាថិនស៍** ( Jonathan Martens )
ប្រធានអង្គភាពជំនួយទេសន្តរជន ការិយាល័យប្រចាំតំបន់សម្រាប់
អាស៊ីនិងប៉ាស៊ីហ្វិក អង្គការទេសន្តរប្រវេសន៍អន្តរជាតិ ( IOM )
( សហប្រធាន )

---

**មីហ្គិន ឆាលមើរស៍** ( Megan Chalmers )
មន្ត្រីច្បាប់ជាន់ខ្ពស់ ផ្នែកឧក្រិដ្ឋកម្មប្រឆាំងមនុស្ស
មហាអយ្យការ ប្រទេសអូស្ត្រាលី

---

**ម៉ូហាមិត ស៊ិហ្វាន** ( Mohamed Shifan )
អនុប្រធាននាយកដ្ឋានអន្តោប្រវេសន៍
ក្រសួងអន្តោប្រវេសន៍និងកិច្ចការចំណាកស្រុក
ប្រទេសមលឌីវស៍

---

**រ៉ូប៊ើត ឡាហ្គា** ( Robert Larga )
ប្រធាននាយកដ្ឋានអាជ្ញាប័ណ្ណនិងនីយ័ត្តកម្ម
កិច្ចការរដ្ឋបាលនៃការងារបរទេសហ្វីលីពីន
ប្រទេសហ្វីលីពីន

---

**ពិនធិប លីឡាគ្រៀងសាក់ ស្រ៊ីសានិត**
( Pinthip Leelakriangsak Srisanit )
ព្រះរាជអាជ្ញា នាយកដ្ឋានកិច្ចការអន្តរជាតិ
មហាអយ្យការ ប្រទេសថៃឡង់

---

ជំនួយបន្ថែមចំពោះគណៈកម្មាធិការព្រាងឯកសារ ផ្តល់ដោយ:
**ធិម ហាវ** ( Tim Howe )
អ្នកសម្របសម្រួលគំរោងការ IOM ការិយាល័យជំនួយការប្រចាំតំបន់

The Bali **Process**

# អារម្ភកថា

ចាប់តាំងពីកកើតនាឆ្នាំ២០០២មក នីតិវិធីក្រុងបាលីស្តីអំពីការរត់ពន្ធមនុស្ស ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនពាក់ព័ន្ធ (ហៅកាត់ថា នីតិវិធីក្រុងបាលី) បានធ្វើឲ្យមានការយល់ដឹងនៅក្នុងតំបន់អំពីផលវិបាកនៃការរត់ពន្ធមនុស្ស ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនដែលពាក់ព័ន្ធ ហើយនិងបានបង្កើតនិងអនុវត្តយុទ្ធសាស្ត្រនិងសហប្រតិបត្តការដើម្បីឆ្លើយតប។ មានប្រទេសជាសមាជិកនិងអង្គការអន្តរជាតិទាំងអស់៤៨ បូកនិងប្រទេសនិងអង្គការអន្តរជាតិក្នុងឋានៈជាអ្នកសង្កេតផង ក៏បានចូលរួមក្នុងវេទិកាដោយស្ម័គ្រចិត្តនេះ។

មន្ត្រីជាន់ខ្ពស់នៅក្នុងកិច្ចប្រជុំលើកទី៨នៃក្រុមអាដហុកក្នុងនីតិវិធីក្រុងបាលី បានស្នើឲ្យការិយាល័យជំនួយការប្រចាំតំបន់នៃនីតិវិធីក្រុងបាលី (Bali Process Regional Support Office) ហៅកាត់ថា RSO បង្កើតសេចក្តីណែនាំមួយចំនួនជាគោលនយោបាយស្តីអំពីបញ្ហាសំគាល់និងការពារជនដែលត្រូវគេជួញដូរ ដោយពិគ្រោះយោបល់ជាមួយនឹងសមាជិកទាំងឡាយណាដែលមានផលប្រយោជន៍ពាក់ព័ន្ធ។ បន្ទាប់ពីមានទិសដៅនេះហើយ RSO បានបង្កើតគណៈកម្មាធិការព្រាងឯកសារមួយដែលមានឥណ្ឌូណេស៊ីនិង IOM ធ្វើសហប្រធានដើម្បីព្រាងសេចក្តីណែនាំជាគោលនយោបាយទាំងនោះ។ គណៈកម្មាធិការព្រាងឯកសារមានអ្នកជំនាញចេញពីរដ្ឋាភិបាលនៃប្រទេសឥណ្ឌូណេស៊ី អូស្ត្រាលី មលឌីវស៍ ហ្វីលីពីន ថៃឡង់ ហើយនិង IOM។

គណៈកម្មាធិការបានជួបជុំគ្នាបួនដងក្នុងរយៈពេល៦ខែ ក្នុងគោលបំណងបង្កើតសេចក្តីណែនាំខ្លីដំបូងសម្រាប់អ្នកសាងគោលនយោបាយនិងអ្នកអនុវត្ត ស្តីអំពីបញ្ហាពាក់ព័ន្ធនឹងការសំគាល់ហើយនិងការការពារជនរងគ្រោះពីការជួញដូរ។ សេចក្តីព្រាងនៃសេចក្តីណែនាំទាំងឡាយនោះត្រូវបានចែកចាយជូនទៅសមាជិកព្រមទាំងអ្នកសង្កេតការណ៍នៃនីតិវិធីក្រុងបាលី ដើម្បីគេអាចផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ហើយនិងសម្រាប់ពិភាក្សានិងពិនិត្យឡើងវិញនៅសិក្ខាសាលាពេញអង្គ នាថ្ងៃ ២៣-២៤ មិនា ឆ្នាំ២០១៥នៅទីក្រុងបាងកកប្រទេសថៃ។ អ្នកចូលរួមទាំងឡាយបានឯកភាពថាសេចក្តីណែនាំជាគោលនយោបាយទាំងនោះជាធនធានមានប្រយោជន៍សម្រាប់អ្នកសាងគោលនយោបាយនិងអ្នកអនុវត្តក្នុងការជួយសំគាល់និងការពារជនរងគ្រោះពីការជួញដូរ។ ឆ្លើយតបទៅនឹងយោបល់ទទួលបានពីសមាជិក គណៈកម្មាធិការព្រាងសេចក្តីបានពិនិត្យសើរើសេចក្តីព្រាងទាំងឡាយនោះដោយមានបញ្ចូលនូវការកែតម្រូវសំខាន់ៗនិងយោបល់ទាំងនោះផង។

សេចក្តីណែនាំជាគោលនយោបាយទាំងឡាយនោះមានបំណងបង្ហាញទិទ្ធភាពរួមនៃស្តង់ដាថ្នាក់អន្តរជាតិនិងតំបន់សម្រាប់សំគាល់និងការពារជនរងគ្រោះពីការជួញដូរ ដោយទាញយកគំរូល្អៗជាច្រើនពីបទពិសោធន៍របស់ប្រទេសជាសមាជិកនៃនីតិវិធីក្រុងបាលី។ ស្របតាមអនុសាសន៍របស់កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៥នាខែមិនាឆ្នាំ២០១៣ សេចក្តីណែនាំជាគោលនយោបាយទាំងឡាយនោះជាជុំទី២នៃសេចក្តីណែនាំជាគោលនយោបាយរបស់នីតិវិធីក្រុងបាលី ហើយដែលស្ថិតក្នុងវង្វង់សាច់រឿងរបស់នីតិវិធីក្រុងបាលីស្តីអំពីបញ្ហានានាដែលសមាជិកនៃនីតិវិធីក្រុងបាលីមានបារម្ភ។ សេចក្តីណែនាំទាំងនោះសម្រាប់ប្រើដោយស្ម័គ្រចិត្ត ពុំមានចំណង ហើយនិងបំពេញបំណងជាឯកសារសម្រាប់ពិគ្រោះរបស់ភ្នាក់ងារទាំងឡាយក្នុងស្រុករបស់រដ្ឋជាសមាជិកនៃនីតិវិធីក្រុងបាលី។

**លីសា ក្រហ្វើត** (Lisa Crawford)
សហប្រធាន RSO (អូស្ត្រាលី)

**ប៊ិប៊ិប អេខេអិន ជុនជូណាន** (Bebeb A.K.N. Djundjunan)
សហប្រធាន RSO (ឥណ្ឌូណេស៊ី)

REGIONAL SUPPORT OFFICE
THE BALI PROCESS

# អក្សរកាត់

| | |
|---|---|
| អាស៊ាន | សមាគមនៃប្រជាជាតិអាស៊ីអគ្នេយ៍ |
| **នីតិវិធីក្រុងបាលី** | នីតិវិធីក្រុងបាលីស្តីអំពីការរត់ពន្ធមនុស្ស ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនដែលពាក់ព័ន្ធ |
| **ILO** | អង្គការពលកម្មអន្តរជាតិ |
| **IOM** | អង្គការទេសន្តរប្រវេសន៍អន្តរជាតិ |
| **អនុសញ្ញាឧក្រិដ្ឋកម្មរៀបចំ** | អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនរៀបចំ |
| **RSO** | ការិយាល័យគាំទ្រប្រចាំតំបន់នៃនីតិវិធីក្រុងបាលី |
| **ពិធីការនៃការជួញដូរមនុស្ស** | ពិធីការទប់ស្កាត់ សង្កត់និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ បន្ថែមទៅលើពិធីការអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនរៀបចំ |
| **UNODC** | ការិយាល័យអង្គការសហប្រជាជាតិសម្រាប់គ្រឿងញៀននិងឧក្រិដ្ឋកម្ម |

# មាតិការឿង


សេចក្តីសង្ខេប 2

ផ្នែកទី១: សេចក្តីផ្តើមអំពីការសំគាល់ជនរងគ្រោះពីការជួញដូរ 3

១.១. នរណាជាជនរងគ្រោះពីការជួញដូរ ? 3

១.២. ការឲ្យនិយមន័យពាក្យជួញដូរមនុស្ស 6

១.៣. ការយល់ដឹងអំពីទម្រង់ទាំងឡាយនៃការកេងប្រវ័ញ្ច 8

ផ្នែកទី២: កាតព្វកិច្ច ផលប្រយោជន៍ និងឧបសគ្គ 12

២.១. ហេតុអ្វីបានជាការសំគាល់សំខាន់ 12

២.២. ការយល់ដឹងថាហេតុអ្វីបានជាជនរងគ្រោះពីការជួញដូរអាចរួញរាក្នុងការបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន 14

ផ្នែកទី៣: វិធីសំគាល់ជនរងគ្រោះ 16

៣.១. អ្នកណាអាចសំគាល់ជនរងគ្រោះពីការជួញដូរ ? 16

៣.២. វិធីជាមូលដ្ឋាន 18

៣.៣. សញ្ញានៃការជួញដូរ 21

ផ្នែកទី៤: ការប្រមូលផ្តុំតម្រុយសម្រាប់សំគាល់ជនរងគ្រោះពីការជួញដូរ 28




# សេចក្តីសង្ខេប

ជនរងគ្រោះពីការជួញដូរជាជនដែលទទួលរងអំពើឧក្រិដ្ឋកម្មនៃការជួញដូរមនុស្សដូចដែលគេឲ្យនិយមន័យក្នុងពិធីការដើម្បីទប់ស្កាត់ សង្កត់ និងដាក់ទោសលើការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ។ ការពុំបានសំគាល់ជនរងគ្រោះពីការជួញដូរបណ្តាលឲ្យការកេងប្រវ័ញ្ចលើជននោះនៅតែមានបន្ត ហើយជននោះមិនអាចទទួលបានជំនួយនិងការការពារដែលគមានសិទ្ធិទទួល។ វាអាចធ្វើឲ្យអាជ្ញាធរពុំអាចប្រមូលពត៌មាននិងភស្តុតាងដែលចាំបាច់សម្រាប់ប្រើក្នុងការប្តឹងអ្នកជួញដូរទាំងនោះដើម្បីរកយុត្តិធម៌។ ដូច្នេះការសំគាល់ជាផ្នែកសំខាន់នៃវិធីទប់ស្កាត់និងផ្តន្ទាទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរនេះ ហើយនិងដើម្បីជួយនិងការពារជនរងគ្រោះ។

អ្នកអនុវត្តអាចមានលទ្ធភាពច្រើនជាងក្នុងការសំគាល់ជនរងគ្រោះពីកាជួញដូរបើកាលណាគេនោះយល់និយមន័យនៃការជួញដូរមនុស្សដែលគេបានចែងនៅក្នុងច្បាប់ ហើយនិងទ្រង់ទ្រាយទាំងឡាយនៃការកេងប្រវ័ញ្ចដែលជនរងគ្រោះអាចទទួល។ ដូច្នេះហើយសេចក្តីណែនាំជាគោលនយោបាយនេះផ្តល់នូវទិទ្ធភាពរួមអំពីការជួញដូរមនុស្ស ហើយនិងទ្រង់ទ្រាយទាំងឡាយរបស់វា។ សម្រាប់គោលបំណងនៃសេចក្តីណែនាំនេះ ‵ការសំគាល់′ ជនរងគ្រោះមានន័យទូលំទូលាយ។ វាមានរាប់បញ្ចូលវិធីស្រង់ឈ្មោះនៅចំណុចជួបគ្នាដំបូង ហើយនិងការផ្តល់ជំនួយនិងការការពារដំបូងនៅពេលជនម្នាក់ត្រូវបានសន្មតថាជាជនរង គ្រោះ។ វាក៏ត្រូវមានការផ្ទៀងផ្ទាត់ឋានៈរបស់ជននោះថាជាជនរងគ្រោះនៅពេលទទួលបានភស្តុតាងនានាបន្ថែមទៀត ហើយក្នុងករណីខ្លះបានជាការបញ្ជាក់ជាផ្លូវការផងបន្ទាប់ពីនីតិវិធីកាត់ទោសបានសម្រេចហើយ។

ការសំគាល់ជនរងគ្រោះពីការជួញដូរតែងតែជាការលំបាក ដូច្នេះហើយសេចក្តីណែនាំនេះស្នើឲ្យរដ្ឋទាំងឡាយប្រើកំរិតទាបនៅពេលធ្វើចំណាត់ថ្នាក់ជនណាម្នាក់ថាជាជនរងគ្រោះ។ ចំណុចនេះមានប្រយោជន៍ណាស់នៅពេលជួបគ្នាលើកទី១ មុនពេលអាជ្ញាធរមានពេលគ្រប់គ្រាន់ក្នុងការបង្កើតឲ្យមានការទុកចិត្តពីអ្នកដែលយើងសង្ស័យ។ នៅពេលបុគ្គលម្នាក់ត្រូវបានសន្មតថាជាជនរងគ្រោះ គេនោះត្រូវទទួលបាននូវការឧបត្ថមនិងការការពារ។ ប្រសិនបើក្រោយមក ឃើញថាការសន្មតនោះមិនមានមូលដ្ឋានត្រឹមត្រូវទៅវិញ នោះការឧបត្ថមនិងការការពារអាចកាត់បន្ថយស្របទៅតាមសេចក្តីត្រូវការឬក៏ដកចេញវិញតែម្តង។

ក្នុងកម្មវិធីសំគាល់ ការមើលសញ្ញានៃការជួញដូរអាចជួយនៅពេលចាប់ផ្តើមដំបូងដើម្បីធ្វើការសើបអង្កេតបន្ថែមទៀត។ សេចក្តីណែនាំនេះស្នើនូវការប្រើសញ្ញាគំរូមួយចំនួន រួមទាំងសញ្ញាទាក់ទងនឹងការកេងប្រវ័ញ្ចក្នុងទ្រង់ទ្រាយជាច្រើនខុសៗគ្នាដែលអាចជួយអ្នកអនុវត្តក៏ដូចជាអ្នកមិនមានជំនាញក្នុងការសំគាល់ជនរងគ្រោះពីការជួញដូរ។ រដ្ឋទាំងឡាយគួររក្សាឲ្យទាន់សម័យ ដូរតាមស្ថានការណ៍ ហើយនិងដាក់កំរិតទម្ងន់សញ្ញាទាំងនោះដើម្បីផ្តល់ទៅអង្គភាពនានាដែលពាក់ព័ន្ធ រួមទាំងអ្នកមិនមានជំនាញផង នូវសេចក្តីណែនាំមួយដែលគេនិងត្រូវការក្នុងស្ថានការណ៍ដែលគេមុខជានឹង ជួប។ ទោះបីរដ្ឋមានបន្ទុកចំបងក្នុងការសំគាល់ជនរងគ្រោះពីការជួញដូរ អង្គការក្រៅរដ្ឋាភិបាលនិងសង្គមស៊ីវិលជាធនធានមិនអាចកាត់តម្លៃបានក្នុងវិធីសំគាល់ ហើយគួរទទួលការគាំទ្រក្នុងតួនាទីយ៉ាងសំខាន់ក្នុងការស្តាបនាទំនុកចិត្តនិងទំនាក់ទំនងល្អរវាងជនរងគ្រោះនិងអាជ្ញាធរ។ ភ្នាក់ងារអាជ្ញាធរជួរមុខរបស់រដ្ឋ រួមទាំងមន្ត្រីមើលការអនុវត្តច្បាប់ព្រំដែន អន្តោប្រវេសន៍ កិច្ចការគ្រប់គ្រងពលកម្ម ហើយនិងសេវាសង្គម គួរតែទទួលបានការបង្ហាត់បង្រៀនដើម្បីមានជំនាញសម្រាប់សំគាល់ជនរងគ្រោះដោយមានគិតអំពីលក្ខណៈមនុស្សម្នាក់ៗហើយនិងគោរពការណ៍សម្ងាត់របស់គេ។ អ្នករស់នៅក្នុងសហគមន៍ក៏គួរឲ្យយល់ដឹងអំពីសភាពការណ៍និងចំណេះក្នុងការសំគាល់ជនសន្មតថាជាជនរងគ្រោះដើម្បីផ្តល់ដំណឹងទៅអាជ្ញាធរនានាសមស្រប។

# ផ្នែកទី១:
## សេចក្តីផ្តើមនៃការសំគាល់ជនរងគ្រោះពីការជួញដូរ
### ១.១. នរណាជាជនរងគ្រោះពីការជួញដូរ ?

ការជួញដូរមនុស្សជាអំពើខុសច្បាប់ដែលមានទ្រង់ទ្រាយច្រើនយ៉ាង ហើយមានលក្ខណៈខុសៗគ្នាពីតំបន់មួយទៅតំបន់មួយ។ បុរស ស្ត្រី និងកុមារត្រូវបានគេកេងប្រវ័ញ្ចក្នុងគ្រប់វិស័យរួមទាំងវិស័យកសិកម្ម សំណង់ ថែទាំនិងទទួលភ្ញៀវ ការងារក្នុងផ្ទះ វិស័យកំសាន្តនិងកីឡា ព្រៃឈើ នេសាទ រ៉ែ និងតម្បាញ។ គេអាចកេងប្រវ័ញ្ចលើមនុស្សនៅពេលអ្នកទាំងនោះឆ្លងដែនពីប្រទេសមួយទៅប្រទេសមួយ ឬក៏ស្ថិតក្នុងប្រទេសរបស់ខ្លួន។ ទោះបីមានកត្តាជាច្រើនដែលធ្វើឲ្យមនុស្សងាយស្រួលគេជួញដូរ ក្រុមដែលមានហានិភ័យខ្ពស់រួមមានជនអន្តោប្រវេសន៍ដែលពុំមានចុះឈ្មោះក្នុងបញ្ជី  ជនជាតិភាគតិច ហើយនិងកុមារដែលពុំមានឪពុកម្តាយឬអ្នកអាណាព្យាបាល។ កត្តាទាំងឡាយដូចជាភាពក្រីក្រ ការពុំមានការងារធ្វើ វិសមភាពយែនឌ័រកង្វះនៃការទទួលបានឱកាសអប់រំនិងធនធាននានា ហើយនិងការដែលគ្មានការចុះសំបុត្រកំណើតជាលក្ខណៈប្រព័ន្ធ ក៏ជាកត្តាបង្កើនឲ្យងាយគេជួញដូរ។

អ្នកណាក៏អាចក្លាយជាជនរងគ្រោះពីការជួញដូរ ដោយគ្មានគិតអំពីអាយុ ភេទ ចំណង់ចំណូលចិត្តវិស័យភេទ សញ្ជាតិ ជាតិសាសន៍ឬប្រភេទសង្គមដែលខ្លួនកើតចេញមក ភាពពិការ ឬក៏កាលៈទេសៈ។ និយាយឲ្យងាយស្តាប់បំផុត ជនរងគ្រោះពីការជួញដូរគឺជាជនដែលបានរងគ្រោះអំពីឧក្រិដ្ឋកម្មនៃការជួញដូរមនុស្ស។ ដូចមានចែងខាងក្រោមក្នុងផ្នែក ១.២ ពិធីការដើម្បីទប់ស្កាត់ សង្កត់ និងដាក់ទោសលើការជួញដូរមនុស្សជាពិសេសស្ត្រីនិងកុមារ (ហៅកាត់ថាពិធីការអំពីការជួញដូរមនុស្ស) ផ្តល់និយមន័យអន្តរជាតិអំពីឧក្រិដ្ឋកម្មក្នុងការជួញដូរមនុស្ស។
ពេលអនុវត្ត ការសំគាល់ថាអ្នកណាជាជនរងគ្រោះពីឧក្រិដ្ឋកម្មមិនមែនតែងតែស្រួលគ្រប់ពេលឡើយ។ ឧបសគ្គរួមមាន បញ្ហាក្នុងការទំនាក់ទំនងពាក់ព័ន្ធនិងភាសានិងវប្បធម៌ ហើយនិងភាពរួញរារបស់ជនរងគ្រោះក្នុងការនិយាយជាមួយអាជ្ញាធរដោយសារខ្លាច ឬការមិនទុកចិត្ត ជាពិសេសនៅពេលជួបដំបូង។ អាស្រ័យទៅលើបទពិសោធន៍របស់គេ គេអាចមិនយល់ថាគេត្រូវបានគេជួញដូរឬក៏កេងប្រវ័ញ្ចឡើយ។ អ្នកខ្លះអាចជឿថាគេបានឯកភាពនឹងស្ថានភាពដែលខ្លួនគេស្ថិតក្នុង ទោះបីគេប្រើការកៀបសង្កត់ បង្ខិតបង្ខំ ឬក៏កេងប្រវ័ញ្ចក្នុងការឲ្យយល់ព្រមនោះក៏ដោយ។ ដោយសារហេតុនេះនិងហេតុផ្សេងៗទៀត មានជនរងគ្រោះជាច្រើនគេពុំបានរកឃើញថាជាជនរងគ្រោះរហូត។ វាជាទម្លាប់ល្អក្នុងការសន្មតថាជនម្នាក់ជាជនរងគ្រោះពីការជួញដូរបើមានការសង្ស័យថាជននោះអាចស្ថិតក្នុងស្ថានភាពនោះ។ អនុវត្តតាមការសន្មតនោះមានន័យថា កាលណាមានការសង្ស័យថាជនម្នាក់អាចជាជនរងគ្រោះពីការជួញដូរមនុស្ស អាជ្ញាធរនិងគិតថាជននោះត្រូវការជំនួយហើយនិងការការពារ។ ប្រសិនបើក្រោយមក បញ្ជាក់ឃើញថាជននោះមិនមែនជាជនរងគ្រោះពីការជួញដូរហើយមិនមានតម្រូវការជំនួយឬការការពារ ការឧបត្ថមអាចដកចេញនៅពេលនោះ។ ជនដែលមានសញ្ញាថាមានគេជួញដូរ អាចជាជនរងគ្រោះក្នុងឧក្រិដ្ឋកម្មផ្សេងទៀតដែរ ដូចជាការវាយតប់ ការចាប់រំលោភ ឬក៏ការចាប់ជំរិត។ បើសិនបញ្ជាក់ឃើញថាជននោះមិនមែនជាជនរងគ្រោះពីការជួញដូរ ប៉ុន្តែជាជនរងគ្រោះពីឧក្រិដ្ឋកម្មផ្សេងវិញ គេអាចបញ្ជូនអ្នកនោះឲ្យទៅទទួលសេវាផ្សេងដែលត្រូវជាង។ ជនរងគ្រោះពីការជួញដូរអាចស្ថិតនៅក្រៅប្រទេសដើមរបស់ខ្លួន ហើយអាចមានការភ័យខ្លាចពិតអំពីការកាប់សម្លាប់នៅប្រទេសរបស់ខ្លួនដោយកត្តាពូជសាសន៍ សាសនា សញ្ជាតិ ជាសមាជិកនៃសង្គមពិសេសណាមួយឬក្រុមដែលមាននិន្នាការនយោបាយណាមួយ។ ក្នុងករណីបែបទាំងនេះ គេត្រូវបញ្ជូនឲ្យទៅធ្វើការសុំសិទ្ធិជ្រកកោន។

> តម្រុយ   :
> បញ្ចូលការសន្មតដែលធ្វើឲ្យយើងធ្វើអ្វីៗហាក់ដូចជាអ្នកដែលគេបានសន្មតថាជាជនរងគ្រោះនោះជាជនរងគ្រោះពិត។
>
> គោលនយោបាយរបស់រដ្ឋគួរអនុញ្ញាត្តិឲ្យអាជ្ញាធរដែលសង្ស័យថាជនម្នាក់ជាជនរងគ្រោះពីការជួញដូរចាត់វិធានការតាមការសង្ស័យនោះគឺគិតថាជននោះជាជនរងគ្រោះដើម្បីផ្តល់ជំនួយនិងការការពារដំបូង។



[1] នៅក្នុងឯកសារនេះទាំងមូល ពាក្យថា `ការជួញដូរមនុស្ស' (human trafficking) គឺប្រើសម្រាប់រៀបរាប់ការជួញដូរមនុស្សដូចដែលគេឲ្យនិយមន័យក្នុងប្រការ៣នៃពិធីការដើម្បីទប់ស្កាត់ សង្កត់ និងដាក់ទណ្ឌកម្ម ការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ (the Protocol to Prevent, Suppress and Punish Trafficking in Persons, Especially Women and Children) ពិធីការនៃការជួញដូរមនុស្ស (Trafficking in Persons Protocol)។

## តម្រុយ: បង្កើនការយល់ដឹងអំពីឧក្រិដ្ឋកម្មនៃការជួញដូរមនុស្ស

ជនដែលគេមិនយល់ថាជាជនរងគ្រោះពីការជួញដូរអាចជាជនរងគ្រោះពីឧក្រិដ្ឋកម្មផ្សេងទៀត ហើយត្រូវការជំនួយនិងការការពារ។ អ្នកអនុវត្តដែលទទួលបន្ទុកក្នុងការសំគាល់ជនរងគ្រោះពីការជួញដូរគួរទទួលការយល់ដឹងអំពីប្រភេទនៃឧក្រិដ្ឋកម្មពាក់ព័ន្ធទាំងឡាយ ហើយមានបំពាក់អ្វីៗតបតាមសេចក្តីត្រូវការ។

មនុស្សទាំងឡាយដែលឆ្លងកាត់ការជួញដូរមនុស្សជាជនរងគ្រោះពីឧក្រិដ្ឋកម្ម ហើយរដ្ឋត្រូវគិតដូចនោះនិងផ្តល់ការការពារ។ បន្ថែមទៅលើការរងគ្រោះពីឧក្រិដ្ឋកម្ម ជនរងគ្រោះពីការជួញដូរអាចឆ្លងកាត់ការបំពានធ្វើបាបផ្នែកសិទ្ធិមនុស្ស និងផ្នែកផ្សេងទៀតរួមទាំងការធ្វើឲ្យរបួសកាយ របួសផ្លូវចិត្ត ការគ្រាំគ្រាផ្លូវចិត្ត ការទទួលភាពអាមាសឬស្នាមអាមាស ហើយនិងការខាតបង់សេដ្ឋកិច្ច។ គេនៅតែត្រូវគិតថាជនម្នាក់ជាជនរងគ្រោះទោះបីអ្នកជួញដូរត្រូវគេស្គាល់ ចាប់បាន ឬ តុលាការថ្កោលទោសឬកាត់ទោសឬគ្មានក៏ដោយ ហើយទោះបីមានឬគ្មានទំនាក់ទំនងជាសាច់ញាតិរវាងជនរងគ្រោះនិងជនសង្ស័យថាជាអ្នកជួញដូរក៏ដោយ។

### តារាងទី១: ជំនឿខុសនិងអ្វីជាការពិតក្នុងការសំគាល់ជនរងគ្រោះ [2]

| ជំនឿខុស | អ្វីជាការពិត | សម្រាប់ពត៌មានបន្ថែម សូមមើល |
|---|---|---|
| មនុស្សត្រូវឆ្លងដែនអន្តរជាតិទើបគេថាជាជនរងគ្រោះពីការជួញដូរ | ទោះបីមនុស្សជាច្រើនត្រូវបានគេជួញដូរឆ្លងកាត់ព្រំដែនអន្តរជាតិ ការជួញដូរមនុស្សក៏អាចធ្វើក្នុងប្រទេសតែមួយដែលគេហៅថាការជួញដូរក្នុងស្រុក | *១.១. និយមន័យនៃពាក្យជួញដូរមនុស្ស* |
| មានតែស្រ្តីនិងកុមារទេអាចជាជនរងគ្រោះ | ការស្រាវជ្រាវនិងការផ្សព្វផ្សាយពត៌មានអំពីការជួញដូរមនុស្សបានផ្តោតទៅលើការជួញដូរស្រ្តីនិងកុមារ។ ប៉ុន្តែបុរសក៏គេជួញដូរក្នុងការកេងប្រវ័ញ្ចគ្រប់ប្រភេទដែរ ជាពិសេសប្រភេទដែលប្រើពលកម្មដោយបង្ខិតបង្ខំ។ | *១.២. និយមន័យនៃពាក្យជួញដូរមនុស្ស*<br>*១.៣. ការយល់ដឹងទម្រង់ទាំងឡាយនៃការកេងប្រវ័ញ្ច* |
| គ្រប់ជនរងគ្រោះទាំងអស់នៃការជួញដូរគេធ្វើឡើងសម្រាប់កេងប្រវ័ញ្ចផ្លូវភេទ | ទោះបីភាគច្រើនការជួញដូរធ្វើសម្រាប់កេងប្រវ័ញ្ចផ្លូវភេទ មនុស្សត្រូវគេជួញដូរសម្រាប់*ពលកម្មដោយបង្ខិតបង្ខំ ធ្វើទាសករឬក៏ធ្វើការប្រហាក់ប្រហែលនឹងទាសករ សេវជន ឬក៏ការយកសរីរាង្គចេញនិងការកេងប្រវ័ញ្ចប្រភេទឯទៀតៗ* | *១.៣. ការយល់ដឹងទម្រង់ទាំងឡាយនៃការកេងប្រវ័ញ្ច* |

[2] ពត៌មានបន្ថែមទាក់ទងនឹងចំណុចទាំងឡាយដែលបានលើកឡើងក្នុងតារាងនេះ គេអាចមើលនៅក្នុងឯកសារ របាយការណ៍ពិភពលោកអំពីការជួញដូរមនុស្ស: (Global Report on Trafficking in Persons), UNODC, 2014; ILO ការប៉ាន់ស្មានសម្រាប់ទូទាំងពិភពលោកនៃពលកម្មដោយបង្ខិតបង្ខំ២០០២ (Global Estimate of Forced Labour) :លទ្ធផលនិងវិធីធ្វើ (Results and Methodology) ILO, 2012; របាការណ៍អំពីការជួញដូរមនុស្ស ២០១៤ (Trafficking in Persons Report 2014) រដ្ឋាភិបាលសហរដ្ឋអាមេរិក នាយកដ្ឋាននៃរដ្ឋ ការិយាល័យនៃការស្ទង់និងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ឆ្នាំ២០១៤

| | | |
|---|---|---|
| គ្រប់អ្នកធ្វើការក្នុងឧស្សាហកម្មផ្លូវភេទទាំងអស់ជាជនរងគ្រោះនៃការជួញដូរ | ទោះបីការជួញដូរសម្រាប់កេងប្រវ័ញ្ចផ្លូវភេទជាការជួញដូរមួយដែលគេឧស្សាឃើញជាងគេ អ្នកធ្វើការក្នុងឧស្សាហកម្មផ្លូវភេទមិនមែនសុទ្ធសឹងជាអ្នកគេជួញដូរទេ។ គេត្រូវមានប្រើមធ្យោបាយដែលហាមឃាត់ដូចជាការកៀបសង្កត់ គំរាម បោកប្រាស (បើជនរងគ្រោះជាមនុស្សពេញវ័យ)ដើម្បីបញ្ជាក់ថាគេត្រូវបានជួញដូរសម្រាប់គោលបំណងផ្លូវភេទ។ | *១.៣. ការយល់ដឹងទម្រង់ទាំងឡាយនៃការកេងប្រវ័ញ្ច*<br><br>*៣.៣. សញ្ញានៃការជួញដូរ* |
| គ្រប់ទេសន្តរជនទាំងអស់ដែលពុំមានឈ្មោះក្នុងឯកសារជាជនរងគ្រោះនៃការជួញដូរ | ទោះបីជនរងគ្រោះអាចត្រូវគេនាំចូលដោយមិនប្រក្រដីក្នុងប្រទេសដែលគេកេងប្រវ័ញ្ច មិនមែនមនុស្សគ្រប់រូបដែលចូលក្នុងប្រទេសមួយដោយមិនប្រក្រដីសុទ្ធតែត្រូវគេកេងប្រវ័ញ្ចទេ។ បន្ថែមពីលើនេះទៀត មនុស្សដែលធ្វើដំណើរទៅឬបន្តស្នាក់នៅក្នុងប្រទេសមួយដោយប្រក្រដីក៏អាចជាជនរងគ្រោះពីការជួញដូរដែរ។ | *១.២. និយមន័យនៃពាក្យជួញដូរមនុស្ស*<br><br>*២.២. យល់ដឹងថាហេតុអ្វីបានជាជនរងគ្រោះពីការជួញដូរអាចរួញរាក្នុងការបញ្ជាក់អំពីខ្លួនឯង*<br><br>*៣.៣. សញ្ញានៃការជួញដូរ* |
| អ្នកដែលដឹងឬបង្ហាញថាខ្លួនយល់ព្រមចំពោះ ស្ថានភាពរបស់ខ្លួនមិនអាចរាប់ថាជាជនរងគ្រោះពីការជួញដូរទេ | ទោះបីជនម្នាក់បង្ហាញថាខ្លួនទទួលយល់ព្រមនឹងស្ថានភាព(ឧទាហរណ៍ ការងារធ្វើ) តាំងពីដំបូងទីជននោះអាចជាជនរងគ្រោះពីការជួញដូរ។<br><br>ការយល់ព្រមពីកុមារមិនអាចយកជាបានការជានិច្ច ហើយការយល់ព្រមពីមនុស្សពេញវ័យ មិនអាចយកជាបានការទេបើគេបានប្រើមធ្យោបាយដែលហាមឃាត់ដូចជាការកៀបសង្កត់ ការគំរាមកំហែង ឬការបោកប្រាសដើម្បីទទួលបានការយល់ព្រមនោះ។ | *១.២. និយមន័យនៃពាក្យជួញដូរមនុស្ស*<br><br>*៣.៣. សញ្ញានៃការជួញដូរ* |
| អ្នកដែលជាប់សាច់ញាតិ ឬមានទំនាក់ទំនងស្នេហាជាមួយនឹងអ្នកជួញដូររបស់ខ្លួន មិនអា ចរាប់ថាជាជនរងគ្រោះពីការជួញដូរទេ | ជារឿយៗជនរងគ្រោះត្រូវគេល្បួងឬលើកដំកើងឲ្យចូលក្នុងស្ថានភាពជួញដូរដោយមិត្តភ័ក្តឬបងប្អូន។ អាពាហ៍ពិពាហ៍ ឬទំនាក់ទំនងជិតស្និតដទៃទៀតក៏ជាមធ្យោបាយដែលអ្នកជួញដូរប្រើសម្រាប់គ្រប់គ្រងជនរងគ្រោះរបស់គេ។ ការគោរពទាំងងងឹតងងល់ឬអាពាហ៍ពិពាហ៍ដោយបង្ខំក៏រាប់ថាជាសកម្មភាពប្រហាក់ប្រហែលនិងទាសភាពដែរ។[13] | *៣.៣. សញ្ញានៃការជួញដូរ* |
| អ្នកដែលជឿថាជីវិតរបស់ខ្លួនស្រួលជាងមុនឬមានលុយជាងមុនមិនអាចរាប់ថាជាជនរងគ្រោះពីការជួញដូរទេ | ជនម្នាក់អាចជាជនរងគ្រោះពីការជួញដូរទោះបីគេនោះមានប្រាក់ខែច្រើនជាងនិង/ឬជីវិតស្រួលជាងមុនពីកាលត្រូវបានគេជួញដូរ។ គេត្រូវ វាយតម្លៃការកេងប្រវ័ញ្ចដោយមិនលំអៀង។ | *២.២. យល់ដឹងថាហេតុអ្វីបានជាជនរងគ្រោះពីការជួញដូរអាចរួញរាក្នុងការបង្ហាញ ខ្លួន*<br><br>*៣.៣. សញ្ញានៃការជួញដូរ* |

[3] ឃ្លា `សកម្មភាពប្រហាក់ប្រហែលនឹងទាសភាព` គេឲ្យនិយមន័យក្នុង អនុសញ្ញាបន្ថែមស្តីអំពីការលុបបំបាត់ទាសភាព ការលក់ដូរទាសករហើយនិងទំនាមទម្លាប់ប្រហាក់ប្រហែលទាសភាព (Supplementary Convention on the Abolition of Slavery, the Slave Trade, and Institutions and Practices Similar to Slavery) (អនុសញ្ញាបន្ថែម) (Supplementary Convention) នាឆ្នាំ១៩៥៦, ដូចបានលើកមកពិគ្រោះក្នុងផ្នែក ១.៣.

## ១.២. ការឲ្យនិយមន័យពាក្យជួញដូរមនុស្ស

គោលបំណងមួយក្នុងចំណោមគោលបំណងទាំងឡាយដែលមានចែងក្នុងពិធីការជួញដូរមនុស្ស គឺដើម្បីការពារនិងជួយជនរងគ្រោះពីការជួញដូរ ដោយគោរពសិទ្ធរបស់គេដោយពេញលេញ[4]។ គោលបំណងនេះធ្វើឲ្យមានតម្រូវការមិនចំពោះមួយដែលតម្រូវឲ្យរដ្ឋសំគាល់ជនរងគ្រោះដែលអាចត្រូវការជំនួយនិងការការពារ។ ការសំគាល់អ្នកណាជាជនរងគ្រោះពីការជួញដូរតម្រូវឲ្យអាជ្ញាធររបស់រដ្ឋយល់អ្វីទៅជាការជួញដូរមនុស្សដែលផ្អែកលើមូលដ្ឋាននិយមន័យរបស់ឧក្រិដ្ឋកម្មនោះ។ នៅក្នុងច្បាប់អន្តរជាតិ និយមន័យរបស់ឧក្រិដ្ឋកម្មនោះមានចែងក្នុងមាត្រា 3(a) នៃពិធីការស្តីអំពីការជួញដូរមនុស្ស។

> *"ការជួញដូរមនុស្ស" មានន័យថាជាការប្រកាសជ្រើសរើស ដឹកជញ្ជូន ផ្ទេរ ផ្ទុក ឬទទួលមនុស្សដោយប្រើមធ្យោបាយគំរាមឬប្រើកម្លាំងឬកៀបក្នុងទ្រង់ទ្រាយផ្សេងទៀត ឆក់យកមនុស្ស ក្លែងបន្លំ បោកប្រាស ប្រើអំណាចខុស ឬឆ្លៀតឱកាសក្នុងស្ថានភាពទន់ខ្សោយ ឬឲ្យឬទទួលប្រាក់ឬផលប្រយោជន៍ដើម្បីទទួលបាននូវការយល់ព្រមពីជនម្នាក់ដែលមានអំណាចគ្រប់គ្រងលើជនម្នាក់ទៀត ដើម្បីគោលបំណងធ្វើការកេងប្រវ័ញ្ច។ការកេងប្រវ័ញ្ចត្រូវរាប់បញ្ចូលយ៉ាងហោចណាស់ការកេងប្រវ័ញ្ចអំពីពេស្យាចាររបស់អ្នកដទៃ ឬក៏ការកេងប្រវ័ញ្ចផ្លូវភេទតាមទ្រង់ទ្រាយផ្សេងទៀត ពលកម្មឬសេវាដោយបង្ខិតបង្ខំ ទាសភាពឬក៏អំពើប្រហាក់ប្រហែលនឹងទាសភាព ការឲ្យគេប្រើទ្រព្យសម្បត្តិរបស់ខ្លួន ឬក៏ការយកសរីរាង្គចេញ។*

រូបទី១ ខាងក្រោមនេះបង្ហាញជាគោលៗនូវធាតុ៣ដែលត្រូវមានដើម្បីបានជាការជួញដូរមនុស្សពេញវ័យ។ ចេញពីកូឡោននិមួយៗ គេត្រូវការតែធាតុមួយដើម្បីបំពេញឲ្យបានជាការជួញដូរ។

**រូបទី១ : ផ្នែកសំខាន់ៗនៃនិយមន័យតាមលក្ខណៈច្បាប់អន្តរជាតិនៃការជួញដូរមនុស្ស [5]**




[4] ចូរមើលប្រការ ២(ខ) នៃពិធីការនៃការជួញដូរមនុស្ស (the Trafficking in Persons Protocol.)

[5] ប្រភព : សេចក្តីណែនាំជាគោលនយោបាយស្តីអំពីការធ្វើឲ្យការជួញដូរមនុស្សទៅជាឧក្រិដ្ឋកម្ម (Policy Guide on Criminalizing Trafficking in Persons) នីតិវិធីក្រុងបាលី (Bali Process) ឆ្នាំ 2014, ទំព័រ៥

ប្រការ 3(b) នៃ**ពិធីការ**ចែងថាការយល់ព្រមរបស់ជនរងគ្រោះពុំមានន័យអ្វីទេ បើមានការប្រើមធ្យោបាយដែលបានចែងក្នុង**ពិធីការ**នោះត្រូវបានប្រើ។ ប្រការ 3(b) និង 3(c) ចែងថាមធ្យោបាយដែលបានចែងមិនចាំបាច់បញ្ជាក់បង្ហាញឡើយក្នុងករណីជនរងគ្រោះជាកុមារអាយុក្រោម១៨ឆ្នាំ។[6]

ពិធីការនេះមិនមែនជាឯកសារច្បាប់អន្តរជាតិលើកទី១ដែលរៀបរាប់អំពីបញ្ហាការជួញដូរមនុស្សឡើយ ប៉ុន្តែវាផ្តល់នូវនិយមន័យយ៉ាងពេញលេញមកដល់ពេលនេះ ហើយជាឯកសារអន្តរជាតិចំបងដែលភាគីរដ្ឋទាំងឡាយពឹងផ្អែកក្នុងការបង្កើតនិយមន័យឧក្រិដ្ឋកម្មក្នុងច្បាប់ជាតិ។ និយមន័យក្នុងមាត្រា៣ បានជួយធ្វើឲ្យមានស្តង់ដាតែមួយក្នុងការយល់ថាបុរសចាស់និងកុមារអាចជាជនរងគ្រោះពីការជួញដូរមនុស្ស ហើយការកេងប្រវ័ញ្ចមានរាប់បញ្ចូលមិនមែនគ្រាន់តែការកេងប្រវ័ញ្ចផ្លូវភេទប៉ុណ្ណោះទេ គឺការកេងប្រវ័ញ្ចប្រភេទដទៃទៀតផងដែរ[7]។ តារាងប្រភេទទាំងឡាយនៃការកេងប្រវ័ញ្ចចែងនៅក្នុងនិយមន័យ មានរាប់បញ្ចូលពលកម្មឬសេវាដោយការបង្ខិតបង្ខំ ឬទាសភាពឬក៏អំពើប្រហាក់ប្រហែលនឹងទាសភាព ដែលមានផ្តល់និយមន័យក្នុងកន្លែងផ្សេងទៀតក្នុងច្បាប់អន្តរជាតិ ក៏ដូចជាការឲ្យគេប្រើទ្រព្យសម្បត្តិហើយនិងការឲ្យគេយកសរីរាង្គចេញ។ ទោះបីតារាងនេះកំណត់ស្តង់ដាអប្បបរមានៃប្រភេទអំពើដែលចាំបាច់ត្រូវមានដើម្បីសន្មតថាជាការកេងប្រវ័ញ្ច វាមិនបានរៀបរាប់គ្រប់ប្រភេទទាំងអស់ទេ ដែលធ្វើឲ្យនិយមន័យមានភាពទន់ភ្លន់ក្នុងការរាប់បញ្ចូលនូវអំពើកេងប្រវ័ញ្ចដែលមានទម្រង់ថ្មីៗទៀតបាន។

និយមន័យអន្តរជាតិនៃពាក្យជួញដូរមនុស្សមានការបកប្រែច្រើនយ៉ាង។ ខ្លះគិតថាការជួញដូរមនុស្សជាវិធីដែលជនរងគ្រោះត្រូវបានគេយកទៅដាក់ក្នុងការកេងប្រវ័ញ្ច (ការប្រកាសជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្ទុក និងការទទួល) ដោយការកេងប្រវ័ញ្ចស្ថិតនៅជាប់ដោយឡែក។ ខ្លះទៀតយល់ថាឧក្រិដ្ឋកម្មនេះជាអំពើទាំងពីរនោះរួមគ្នា គឺគ្របដណ្តប់ទាំងវិធីទាំងលទ្ធផលចុងចប់(ការកេងប្រវញ្ច)។ ឧទាហរណ៍ ការប្រែតាមតែអត្ថន័យពាក្យស្នើថាចលនាមិនមែនចាំបាច់ជាផ្នែកនៃការជួញដូរឡើយ ប៉ុន្តែបើមិនមាននិយាយអំពីចលនានៅក្នុងការជួញដូរ វាពិបាកបែងចែកការជួញដូរមនុស្សអំពីការកេងប្រវ័ញ្ចប្រភេទផ្សេងៗទៀតដែលបានរៀបរាប់ខាងលើដូចជាពលកម្មដោយការបង្ខិតបង្ខំ ដែលគេឲ្យនិយមន័យនៅកន្លែងផ្សេងមួយទៀតក្នុងច្បាប់អន្តរជាតិ។ បន្ថែមពីលើនេះទៀត ទម្រង់នៃការកេងប្រវ័ញ្ចដែលមានចែងយ៉ាងច្បាស់ៗក្នុងច្បាប់ជាតិមានភាពខុសៗគ្នារវាងរដ្ឋនិមួយៗ។

ក្នុងច្បាប់អន្តរជាតិមានការបែងចែកខុសគ្នាតាមលក្ខណៈច្បាប់រវាងការជួញដូរមនុស្សនិងការរត់ពន្ធទេសន្តរជន[8] (migrant)។ តាមការអនុវត្តជាក់ស្តែង ជាពិសេសនៅពេលមានការជួញដូរមនុស្សឆ្លងដែន គេអាចមានការលំបាកក្នុងការបែងចែករវាងជនរងគ្រោះពីការជួញដូរនិងទេសន្តរជនដែលត្រូវបានគេរត់ពន្ធ ជាពិសេសដោយសារជននោះអាចជាអ្នកដែលគេរត់ពន្ធផងនិងជាជនរងគ្រោះពីការជួញដូរផង[9]។ ទេសន្តរជនដែលគេរត់ពន្ធងាយធ្លាក់ទៅជាជនរងគ្រោះពីការជួញដូរជាទីបំផុត ឬក៏រងការកេងប្រវ័ញ្ចប្រភេទដទៃៗទៀតក្នុងពេលធ្វើដំណើរឬក៏ពេលទៅដល់ប្រទេសទីដៅហើយ។ អ្នកប្រព្រឹត្តល្មើសអាចប្រព្រឹត្តឧក្រិដ្ឋកម្មទាំងពីរក្នុងដំណើរតែមួយ គឺរត់ពន្ធមនុស្សមួយចំនួននិងជួញដូរមួយចំនួនទៀត។ ទោះបីទេសន្តរជនដែលគេរត់ពន្ធ

> **តម្រុយ : សំគាល់ជនរងគ្រោះពីការជួញដូរក្នុងចំណោមក្រុមដែលងាយរងគ្រោះ។**
>
> **មុននឹងចូលទៅដល់ដំណាក់នៃការកេងប្រវ័ញ្ច គេពិបាករកឲ្យឃើញជនរងគ្រោះពីការជួញដូរជាទីបំផុត។ រដ្ឋគួរចាត់ឲ្យមានការចែងនៅក្នុងគោលនយោបាយរបស់ខ្លួននូវមាត្រាដែលគាំទ្រអាជ្ញាធរក្នុងការស្វែងរកជនដែលគេសន្មតជារងគ្រោះក្នុងចំណោមជនដែលងាយរងគ្រោះរួមទាំងទេសន្តរជនដែលរត់ពន្ធផង។**

[6] ចូរមើលផងដែរ សេចក្តីណែនាំជាគោលនយោបាយស្តីអំពីការធ្វើឲ្យការជួញដូរមនុស្សទៅជាឧក្រិដ្ឋកម្ម ឆ្នាំ២០១៤ (Policy Guide on Criminalizing Trafficking in Persons) នីតិវិធីក្រុងបាលី (Bali Process) ឆ្នាំ 2014 ទំព័រ ៤-៥

[7] នៅពេលសន្ធិសញ្ញាឆ្នាំ ១៩០៤ ១៩១០ និង ១៩៣៣ ផ្តោតគំនិតខ្លាំងទៅលើសកម្មភាពនៃការបញ្ជូនស្ត្រីនិងក្មេងស្រីឆ្លងដែនសម្រាប់គោលបំណងពេស្យាចារ ហើយអនុសញ្ញាសម្រាប់សង្កត់ការជួញដូរមនុស្សនិងការកេងប្រវ័ញ្ចក្នុងពេស្យាចាររបស់អ្នកដទៃបានពង្រីកវាឲ្យលើសពីស្ត្រីនិងក្មេងស្រីដើម្បីគ្របដណ្តប់ជនណាក៏បាន 'ពិធីការប៉ាលើម៉ូ' (the Palermo Protocol) ជាឯកសារច្បាប់ស្តីអំពីការជួញដូរលើកទី១ដែលបញ្ចូលទម្រង់នានានៃការកេងប្រវ័ញ្ចដែលមិនមែនទាក់ទងនិងរឿងផ្លូវភេទ។

[8] ការរត់ពន្ធមនុស្សមានន័យថាការយកដើម្បីទទួលបានផលជាថវិកាឬវត្ថុពីការចូលដោយខុសច្បាប់របស់ជនម្នាក់ទៅក្នុងភាគីរដ្ឋមួយដែលជននោះមិនមានសញ្ជាតិឬសិទ្ធិរស់នៅជាអចិន្ត្រៃយ៍យោងតាមប្រការ៣ នៃពិធីការប្រឆាំងនឹងការរត់ពន្ធទេសន្តរជនតាមដីគោក សមុទ្រ និងអាកាស (Protocol against the Smuggling of Migrants by Land, Sea and Air) បន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនរៀបចំ (the United Nations Convention against Transnational Organized Crime)

[9] ចំពោះការពិភាក្សាលំអិតអំពីភាពខុសគ្នាតាមផ្លូវច្បាប់រវាងការជួញដូរមនុស្សនិងការរត់ពន្ធមនុស្សចូរមើល សេចក្តីណែនាំជាគោលនយោបាយស្តីអំពីការធ្វើឲ្យការជួញដូរមនុស្សទៅជាឧក្រិដ្ឋកម្ម (Policy Guide on Criminalizing Trafficking in Persons) នីតិវិធីក្រុងបាលីឆ្នាំ២០១៤ (Bali Process, 2014), ទំព័រ ៨-៩ និងសេចក្តីណែនាំជាគោលនយោបាយស្តីអំពីការធ្វើឲ្យការរត់ពន្ធទេសន្តរជនទៅជាឧក្រិដ្ឋកម្ម (Policy Guide on Criminalizing Migrant Smuggling), នីតិវិធីក្រុងបាលីឆ្នាំ២០១៤ (Bali Process, 2014) ទំព័រ ១០-១១

ធម្មតាព្រមព្រៀងដោយស្ម័គ្រចិត្តជាមួយអ្នករត់ពន្ធ គេទាំងនោះងាយធ្លាក់ជាជនរងគ្រោះពីការជួញដូរ ឬក៏ការកេងប្រវ័ញ្ចនិងឧក្រិដ្ឋកម្មដទៃទៀតជាទីបំផុត (រួមទាំងការកៀបយកប្រាក់ ការបំពាន ការបំពានផ្លូវភេទ ការរំលោភផ្លូវភេទ និងទារុណកម្ម)។ ស្ថានភាពនៃការធ្វើដំណើរនៅក្នុងសកម្មភាពរត់ពន្ធអាចប្រែក្លាយទៅជាជម្រើសដែលដំបូងឲ្យគេរត់ពន្ធខ្លួន ទៅជាឈប់មានន័យទៅវិញ[10]។ ឧទាហរណ៍ ស្ថានភាពគ្រោះថ្នាក់តាមផ្លូវ ធ្វើឲ្យទេសន្តរជនពឹងផ្អែកទៅលើអ្នករត់ពន្ធហើយគ្មានជំរើសអ្វី មានតែបន្តដំណើរទោះបីមានភាពវេទនាយ៉ាងណាក៏ដោយ។ អាស្រ័យទៅលើថាតើគេជួបឃើញស្ថានការណ៍នោះនៅពេលណា ជនទាំងនោះអាចគេចាត់ថាជាជនដែលគេរត់ពន្ធជាជាងជនរងគ្រោះពីការជួញដូរ។ ត្រូវមានវត្តមានបំណងកេងប្រវ័ញ្ចទើបគេចាត់ថាមានឧក្រិដ្ឋកម្មជួញដូរ ប៉ុន្តែធម្មតាភាគច្រើនគេរកឃើញក្រោយពីការកេងប្រវ័ញ្ចកើតឡើងហើយ។ អាជ្ញាធរគួរសម្លឹងរកមើលសញ្ញានៃការជួញដូរក្នុងចំណោមទេសន្តរជនដែលគេរត់ពន្ធដើម្បីទើបអាចរកឃើញជនរងគ្រោះពីការជួញដូរ។

## ១.៣. ការយល់ដឹងទម្រង់ទាំងឡាយនៃការកេងប្រវ័ញ្ច

ជនរងគ្រោះពីការជួញដូរភាគច្រើនគេរកឃើញនៅក្រោយពីមានគេកេងប្រវ័ញ្ច ដូច្នេះហើយគេត្រូវស្គាល់ការកេងប្រវ័ញ្ចក្នុងទម្រង់ផ្សេងៗទាំងឡាយរបស់វានិងដូចដែលគេឲ្យនិយមន័យក្នុងច្បាប់អន្តរជាតិ។ ភស្តុតាងនៃការកេងប្រវ័ញ្ចសំខាន់ណាស់ក្នុងការគាំទ្រការសន្មតថាមានការជួញដូរ។

ក្នុងប្រទេសជាច្រើនមានការផ្តោតអារម្មណ៍ខ្ពស់ចំពោះការជួញដូរដើម្បីកេងប្រវ័ញ្ចខាងផ្លូវភេទ។ កេងប្រវ័ញ្ចខាងផ្លូវភេទជាពិសេសលើស្ត្រីនិងកុមារ ជាបញ្ហាធំទូទាំងពិភពលោក ប៉ុន្តែវាសំខាន់ដែលយើងត្រូវយល់ទម្រង់ទាំងឡាយឯទៀតនៃការកេងប្រវ័ញ្ច។

### ពលកម្មឬសេវាដោយការបង្ខិតបង្ខំ

យោងតាមអនុសញ្ញាឆ្នាំ១៩៣០របស់អង្គការពលកម្មអន្តរជាតិស្តីអំពីពលកម្មដោយការបង្ខិតបង្ខំ ពលកម្មឬសេវាដោយការបង្ខិតបង្ខំសុទ្ធតែជាការងារឬសេវាដែលជនម្នាក់ត្រូវបានគេបង្ខំឲ្យធ្វើដោយការគំរាមក្រោមទោសពិន័យអ្វីមួយ ហើយដែលជននោះមិនបានស្ម័គ្រចិត្តធ្វើដោយខ្លួនឯង។ ការគំរាម(menace) ត្រូវគេបានបកប្រែដោយរាប់បញ្ចូលការកៀបសង្កត់ទាំងផ្លូវកាយទាំងផ្លូវចិត្តពីសំណាក់ចៅហ្វាយនាយ[12] ដូចជាមិនឲ្យបុគ្គលឹកមានឱកាសឡើងឋានៈ ផ្ទេរកន្លែងការងារ ទទួលការងារថ្មី ឬក៏ទទួលបានផ្ទះស្នាក់នៅ[13]។ ការធ្វើការដោយមិនស្ម័គ្រចិត្ត ក៏ជាកត្តាយ៉ាងសំខាន់ក្នុងការបញ្ជាក់អំពីពលកម្មដោយការបង្ខិតបង្ខំ។ ពលកម្មត្រូវបានបង្ខំធ្វើលើកលែងតែអ្នកធ្វើផ្តល់ការឯកភាពដោយសេរីហើយអាចដកវិញបាន។

**ពលកម្មកុមារប្រៀបធៀបទៅនឹងការងារកុមារ**

អនុសញ្ញាឆ្នាំ១៩៧៣របស់អង្គការពលកម្មអន្តរជាតិស្តីអំពីអាយុអប្បបរមាដែលអាចទទួលឲ្យចូលធ្វើការបាន មានរៀបរាប់អំពីពលកម្មកុមារថាជាការងារឬសេវាដែលធ្វើដោយមនុស្សក្រោមអាយុ១៨ឆ្នាំដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាពឬសុវត្ថិភាពរបស់ខ្លួន ឬរារាំងដល់ការសិក្សានិងការហាត់រៀនវិជ្ជាជីវៈរបស់ខ្លួន។ ពលកម្មកុមារខុសអំពីការងារកុមារ ដែលមិនប៉ះពាល់ដល់សុខភាព សុវត្ថិភាព ឬឱកាសរៀនសូត្ររបស់កុមារនោះ។

---

[10] ពិធីការប្រឆាំងនឹងការរត់ពន្ធទេសន្តរជនតាមដីគោក សមុទ្រ និងអាកាស (The Protocol against the Smuggling of Migrants by Land, Sea and Air) (ពិធីការនៃការរត់ពន្ធមនុស្ស) មានរួមទាំងប្រការស្តីអំពីការការពារដោយចាំបាច់ប្រហាក់ប្រហែលនឹងប្រការចែងក្នុង ពិធីការនៃការជួញដូរមនុស្សដែរ។

[11] និយមន័យរបស់អង្គការពលកម្មអន្តរជាតិផ្តល់ឲ្យពាក្យពលកម្មដោយបង្ខិតបង្ខំ ត្រូវបានបញ្ជាក់ម្តងទៀតនៅឆ្នាំ២០១៤ដោយមានការទទួលយកពិធីការភ្ជាប់ទៅនឹងអនុសញ្ញាស្តីអំពីពលកម្មដោយបង្ខិតបង្ខំ។ សន្និបាទអន្តរជាតិស្តីអំពីពលកម្ម អត្ថបទនៃពិធីការភ្ជាប់ទៅនឹងអនុសញ្ញាស្តីអំពីពលកម្មដោយបង្ខិតបង្ខំ ឆ្នាំ១៩៣០ កំណត់ត្រាបណ្តោះអាសន្ន សម័យប្រជុំលើកទី១០៣ ហ្សឺណែវ ឆ្នាំ២០១៤ ប្រការ១(៣)

[12] ILO របាយការណ៍របស់គណៈកម្មាធិការនៃអ្នកជំនាញស្តីអំពីការអនុវត្តអនុសញ្ញានិងអនុសាសន៍ របាយការណ៍ទី៣(ផ្នែក ១ក) (Report of the Committee of Experts on the Application of Conventions and Recommendations, Report III (Part 1A),) កិច្ចប្រជុំស្តីអំពីពលកម្មអន្តរជាតិលើកទី៩០ ហ្សឺណែវ ឆ្នាំ២០០២ ទំព័រ ៩៨

[13] ការស្ទង់មតិជាទូទៅអំពីការលុបបំបាត់ពលកម្មដោយបង្ខិតបង្ខំធ្វើឡើងដោយគណៈកម្មាធិការជំនាញក្នុងការអនុវត្តពិធីការនិងអនុសាន៍ ILC, សម័យប្រជុំលើកទី៦៥ ហ្សឺណែវ ឆ្នាំ១៩៧៩ ឃ្លាទី២១។ ចូរមើលផងដែរការស្ទង់មតិជាទូទៅនៅឆ្នាំ២០០៧អំពីការខំបំបាត់ពលកម្មដោយបង្ខិតបង្ខំ ក្នុងឃ្លាទី ៣៧។

## ទាសភាព និងទម្លាប់ប្រហាក់ប្រហែលទាសភាព

ទាសភាពជាប្រភេទធ្ងន់ធ្ងរជាងគេបំផុតនៃការកេងប្រវ័ញ្ចលើមនុស្ស។ សេរីភាពផុតពីទាសភាពជាបទដ្ឋានមួយក្នុងចំណោមបទដ្ឋានដ៏តិចតួចក្នុងច្បាប់អន្តរជាតិដែលរដ្ឋមិនអាចទុកចោលមិនអើពីបាន មានន័យថាពុំមានកាលៈទេសៈដែលរដ្ឋអនុញ្ញាត្តិឲ្យមានទាសភាពឡើយ។ គេឲ្យនិយមន័យពាក្យទាសភាពដំបូងនៅក្នុងអនុសញ្ញាឆ្នាំ១៩២៦ដើម្បីសង្កត់ការជួញដូរទាសករហើយនិងទាសភាព ថាជាឋានៈឬលក្ខណៈរបស់បុគ្គលដែលអំណាចទាំងអស់ផ្សារភ្ជាប់និងសិទ្ធិក្នុងការមានកម្មសិទ្ធិត្រូវបានគេប្រើ។ តាមឫសគល់របស់វាទាសភាពគឺអំពីរឿងកម្មសិទ្ធិ។ អំណាចភ្ជាប់ទៅនឹងសិទ្ធិក្នុងការមានកម្មសិទ្ធិដែលជាផ្នែកនៃទាសភាពកាលពីបុរាណ នៅតែឃើញមានស្នាមរូបភាពនេះក្នុងទាសភាពសម័យថ្មីដែរ។ សញ្ញាខ្លះនៃទាសភាពដែលមានចែងក្នុងអនុសញ្ញាអំពីទាសភាព រួមមានអំណាចក្នុងការកំណត់ឲ្យជនរងគ្រោះនូវឈ្មោះ សាសនា ប្តីឬប្រពន្ធ ក៏ដូចជាវាសនារបស់កូនចៅរបស់ជននោះ។[15] ទាសភាពអាចមានរាប់បញ្ចូលអាកប្បកិរិយាដែលធ្វើឲ្យអន់ថយនូវសមត្ថភាពទាំងផ្លូវកាយទាំងផ្លូវចិត្តក្នុងការទ្រទ្រង់ជីវិតរបស់ខ្លួន[16] ។

### តម្រុយ: ការសំគាល់ទាសភាព

ទាសភាពមានសញ្ញាឲ្យដឹងតាមរយៈទំនាក់ទំនងរវាងអ្នកប្រព្រឹត្តនិងអ្នករងគ្រោះជាជាងតាមលក្ខណៈនៃស្ថានភាព។ អាជ្ញាធរគួរយល់ថាមនុស្សម្នាក់ដែលស្ថិតក្នុងទាសភាពអាចរស់នៅដោយស្រួល ប៉ុន្តែពុំមានអំណាចក្នុងការសម្រេចកិច្ចការសំខាន់ៗរបស់ខ្លួនឡើយ។

ទម្លាប់ស្រដៀងគ្នានឹងទាសភាពត្រូវបានហាមឃាត់ដោយអនុសញ្ញាបន្ថែមឆ្នាំ១៩៥៦ស្តីអំពីការលុបបំបាត់ទាសភាព ការជួញដូរទាសករ និងប្រពៃណីនិងទម្លាប់ស្រដៀងនិងទាសភាព។ ប្រពៃណីនិងទម្លាប់ស្រដៀងនិងទាសភាព គឺនិយាយអំពីទំនាក់ទំនងបែបកេងប្រវ័ញ្ចរបស់មនុស្ស ដែលមានផ្នែកកម្មសិទ្ធិហើយដែលរក្សានៅមានជីវិតមិនមែនដោយសារច្បាប់ទេ ប៉ុន្តែដោយទំនាម ទំលាប់ ឬទំលាប់សង្គម។ ជាពិសេស អនុសញ្ញាបន្ថែមបានបញ្ជាក់អំពីប្រពៃណីនិងទម្លាប់ស្រដៀងនឹងទាសភាព ដូចតទៅ ៖

- បំណុលសួពូជ (Debt bondage) (ប្រការ 1(a)), ជាស្ថានភាពកើតឡើងដោយកូនបំណុលសន្យាថានឹងផ្តល់សេវាដោយខ្លួនឯងឬដោយអ្នកណាម្នាក់ដែលខ្លួនគ្រប់គ្រងដើម្បីធានាបំណុល បើតម្លៃសេវាទាំងនោះតាមការគិតសមរម្យមិនយកទៅទូទាត់ផាត់បំណុល ឬក៏កំឡុងពេលឬក៏លក្ខណៈនៃសេវាទាំងនោះមិនបានកំណត់ឬបញ្ជាក់។ និយាយម្យ៉ាងទៀត បំណុលសួពូជគឺជាស្ថានភាពដែលមនុស្សម្នាក់ផ្តល់សេវាដើម្បីបង់បំណុលដែលមិនចេះចប់។

### តម្រុយ : ការសំគាល់បំណុលសួពូជ

បំណុលសួពូជជាបញ្ហាឧស្សាហ៍មានក្នុងរង្វង់ជនរងគ្រោះពីការជួញដូរ។ បំណុលសួពូជអាចសំគាល់បានដោយឃើញមានបំណុលដែលមិនអាចគិតដឹងចំនួនហើយមិនអាចបង់ដាច់ទោះបីធ្វើការឬផ្តល់សេវាប៉ុន្មានក៏ដោយ។ អាជ្ញាធរជាច្រើនយល់អំពីបំណុលសួពូជក្នុងន័យទូលំទូលាយ ថាជាការផ្តល់កម្លាំងនិងសេវាដើម្បីសងបំណុលក្នុងស្ថានភាពកេងប្រវ័ញ្ច។

[14] អនុសញ្ញាស្តីអំពីការសង្កត់ការលក់ដូរទាសករនិងទាសភាព (Convention to Suppress the Slave Trade and Slavery), 60 សន្ធិសញ្ញារបស់សម្ព័ន្ធប្រជាជាតិ ភាគ២៥៣ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩២៦ ចូលសពលភាពនៅថ្ងៃទី ៩ ខែមិនាឈ្នា១៩២៧ (អនុសញ្ញាស្តីអំពីទាសភាព)

[15] ចូរមើល ដូចជា Prosecutor v. Kunarac, Kovac and Vukovic, ករណី IT-96-23-T និង IT-96-23/1-T, អង្គវិនិច្ឆ័យឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតសភាបណ្ដឹងតវ៉ានៃប្រទេសយូហ្គោស្លាវី ថ្ងៃទី១២ មិថុនា ២០០២

[16] ចូរមើល ដូចជាសេចក្តីណែនាំស្តីអំពីខ្នាតរង្វាស់ផ្លូវច្បាប់ប់នៃទាសភាពរបស់ Bellagio-Harvard( Bellagio-Harvard Guidelines on the Legal Parameters of Slavery), បណ្ដាញស្រាវជ្រាវអំពី ខ្នាតរង្វាស់ផ្លូវច្បាប់ប់នៃទាសភាពឆ្នាំ ២០១២

- (មាត្រា 1(b)), (ពាក្យអង់គ្លេសថា Serfdom) ជាស្ថានភាពដែលអ្នករស់នៅលើដី ជាប់ចំណងតាមផ្លូវច្បាប់ ប្រពៃណី ឬកិច្ចសន្យា ត្រូវរស់នៅនិងធ្វើការនៅលើដីដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ហើយត្រូវផ្តល់សេវាដែលមានការកំណត់ច្បាស់លាស់ទៅអ្នកនោះ ដោយមានឬមិនមានទទួលប្រាក់កម្រៃ ហើយមិនអាចដូរស្ថានភាពនោះបាន។

- ប្រពៃណីឬទម្លាប់ (មាត្រា 1(c)) ដែល "(i) ស្ត្រីម្នាក់ ដោយគ្មានសិទ្ធិប្រកែក ត្រូវប្រគល់ឲ្យគេ ឬប្រគល់តាមការរៀបការ នៅពេលគេប្រគល់ប្ុរាក់ឬវត្ថុឲ្យទៅឪពុកម្តាយ អ្នកអាណាព្យាបាល ឬក្រុមគ្រួសាររបស់ខ្លួន ឬជនឬក្រុមណាផ្សេងមួយទៀត ឬ (ii) ប្តីរបស់ស្ត្រីម្នាក់ ក្រុមគ្រួសាររបស់ប្តី ឬក្រុមមនុស្សសម្ព័ន្ធរបស់ប្តី មានសិទ្ធិផ្ទេរនាងឲ្យទៅមនុស្សម្នាក់ទៀត ក្នុងតម្លៃប្រាក់ដែលគេបានទទួលឬដោយវិធីផ្សេង ឬ
(iii) ស្ត្រីម្នាក់ដែលពេលប្តីស្លាប់ទៅ ត្រូវគេម្នាក់ទៀតទទួលជាមរតក។

## តម្រុយ: ការសំគាល់អាពាហ៍ពិពាហ៍ ដោយបង្ខិតបង្ខំ

ចាប់តាំងពីអនុសញ្ញាបន្ថែមស្តីអំពីទាសភាពចូលជាធរមានមក ដែលអនុសញ្ញានោះសំគាល់តែអាពាហ៍ពិពាហ៍ដោយបង្ខិតបង្ខំទៅលើស្ត្រី គេបានទទួលស្គាល់យ៉ាងទូលំទូលាយថាកុមារានិងបុរសពេញវ័យក៏អាចគេបង្ខំឲ្យរៀបការដែរ។ ដើម្បីប្រយុទ្ធប្រឆាំងគ្រប់ទ្រង់ទ្រាយនៃអាពាហ៍ពិពាហ៍ដោយបង្ខិតបង្ខំ គួរធ្វើច្បាប់ហាមការរៀបការដោយបង្ខិតបង្ខំយ៉ាងណាដែលអាចអនុវត្តបានស្មើភាពគ្នាដោយមិនគិតអំពីភេទរបស់ជនរងគ្រោះ។

ការលក់កុមារសម្រាប់ឲ្យគេកេងប្រវ័ញ្ច (មាត្រា 1(d)),17 ដែលឪពុកម្តាយឬអាណាព្យាបាលរបស់កុមារអនុញ្ញាត្តិឲ្យភាគីទីពកេងប្រវ័ញ្ចពលកម្មរបស់កុមារ។ ច្បាប់ថ្មីៗបានផ្តល់និយមន័យទូលំទូលាយជាងនិយមន័យចែងក្នុងអនុសញ្ញាបន្ថែម។ អនុសញ្ញាអង្គការពលកម្មអន្តរជាតិឆ្នាំ១៩៩៩ ស្តីអំពីទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ បានបន្ថែមការយកចូលដោយបង្ខំនូវកុមារដើម្បីប្រើក្នុងជម្លោះប្រដាប់ដោយអាវុធ រូបអាសអាភាស សកម្មភាពខុសច្បាប់ដូចជាការផលិតនិងការចរាចរគ្រឿងញៀណ ហើយនិងការងារដែលមានលក្ខណៈ ឬដោយសារកាលៈទេសៈដែលត្រូវធ្វើនោះ មុខជានឹងបង្កគ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាព ឬសីលធម៌របស់កុមារ។ ប្រការ 2(a) នៃពិធីការមិនបង្ខំឆ្នាំ ២០០២ របស់អនុសញ្ញាអំពីសិទ្ធិកុមារក្នុងវិស័យលក់កុមារ ពេស្យាចារកុមារ និងរូបអាសអាភាសកុមារ បានឲ្យនិយមន័យទូលំទូលាយលើពាក្យ "លក់កុមារ" ថាជាអំពើ ឬកិច្ចការជំនួញ ដែលធ្វើឲ្យកុមារត្រូវបានគេផ្ទេរដោយមនុស្សម្នាក់ឬក្រុមមួយទៅឲ្យមនុស្សឬក្រុមមួយទៀតសម្រាប់ប្រាក់កម្រៃឬថ្នូនឹងអ្វីមួយ 18។

## តម្រុយ: ការសំគាល់ការលក់កុមារ សម្រាប់ឲ្យគេកេងប្រវ័ញ្ច

ដោយសារការលក់កុមារឬទារកមិនត្រូវការឲ្យឃើញការកេងប្រវ័ញ្ចកើតឡើងបន្ទាប់ពីការលក់ រដ្ឋទាំងឡាយគួរពិចារណាពង្រីកចំណុចនេះបញ្ចូលសកម្មភាពឯទៀតៗដូចជាការលក់កុមារដើម្បីឲ្យគេចិញ្ចឹមហើយនិងកម្មវិធីពាណិជ្ជកម្មចិញ្ចឹមកូនក្នុងពោះឲ្យគេ។[19]

[17] គោលគំនិតទាំងនេះ ដែលមានឈ្មោះមួយទៀតហៅថាសេវកភាព (Servitude) គេឲ្យនិយមន័យក្នុងច្បាប់អន្តរជាតិដែលអាចមានប្រយោជន៍ក្នុងការសំគាល់ស្ថានភាពកេងប្រវ័ញ្ច

[18] ពិធីការមិនបង្ខំភ្ជាប់ទៅនឹងអនុសញ្ញាស្តីអំពីការលក់កុមារ ពេស្យាចារកុមារនិងរូបអាសអាភាសកុមារ (Optional Protocol to the Child Convention on the Sale of Children, Child Prostitution and Child Pornography), 2171
សន្ធិសញ្ញាអង្គការសហប្រជាជាតិភាគ២២៧ ចុះថ្ងៃទី២៥ ឧសភា ឆ្នាំ២០០០ ចូលមានសុពលភាពថ្ងៃទី ១៩ មករា ២០០២ ប្រការ ២(ក)

[19] ចូរមើលបន្ថែម Anne T. Gallagher, 'ប្រការ ៣៥' ក្នុង Phillip Alston and John Tobin, ការបញ្ចេញមតិលើអនុសញ្ញាស្តីអំពីសិទ្ធិរបស់កុមារ (Commentary to the Convention on the Rights of the Child,) Oxford University Press, នាឆ្នាំ២០១៥ ខាងមុខ។ ចូរមើលផងដែរ សេចក្តីពិភាក្សាវែកញែកអំពីការយកធ្វើជាកូនចិញ្ចឹមដោយបង្ខិតបង្ខំ/ខុសច្បាប់ នៅ ២.៣ ខាងក្រោម

## ការយកសរីរាង្គចេញ

ការជួញដូរមនុស្សដើម្បីយកសរីរាង្គចេញអាចកើតឡើងក្នុងបរិបទនៃការលក់ដូរសរីរាង្គសម្រាប់ប្តូរសរីរាង្គរបស់អ្នកបង់វិភាគទាន  ក៏ដូចជាក្នុងបរិបទវប្បធម៌ឬជំនឿដែលអាចពាក់ព័ន្ធនឹងការយកចេញនូវផ្នែកនៃខ្លួនថែមទៅលើសរីរាង្គ។ នៅក្នុងរដ្ឋខ្លះ ច្បាប់ប្រឆាំងនឹងការជួញដូរឈានហួសអំពីការយកសរីរាង្គចេញដើម្បីបញ្ចូលផ្នែកនៃខ្លួនមនុស្ស( ដើម្បីចាប់យកទម្លាប់វប្បធម៌និងសាសនា ) ក៏ដូចជាកោសិកានិងទឹកក្នុងខ្លួន( ដើម្បីចាប់យកស្ថានភាពនៃរបរចិញ្ចឹមកូនក្នុងពោះឲ្យគេ )។  ការជួញដូរសម្រាប់គោលបំណងយកសរីរាង្គចេញបង្កឲ្យមានការលំបាកក្នុងការសំគាល់ ដោយសារអំពើកេងប្រវ័ញ្ចកើតឡើងតែមួយដង គឺផ្ទុយអំពីការកេងប្រវ័ញ្ចក្នុងទម្រង់ផ្សេងៗទៀតដែលអាចត្រូវមានការផ្តល់ពលកម្មឬសេវាជាប្រចាំ។[20]

## ទម្រង់ដទៃទៀតនៃការកេងប្រវ័ញ្ច

យ៉ាងហោចណាស់រដ្ឋទាំងឡាយគួរយល់អំពីការកេងប្រវ័ញ្ចដែលមានទម្រង់ដូចមានចែងយ៉ាងច្បាស់ក្នុងមាត្រា 3 ( a ) របស់**ពិធីការនៃការជួញដូរមនុស្ស**។ ទម្រង់ដទៃទៀតនៃការកេងប្រវ័ញ្ចដែលគេជួបប្រទះជាក់ស្តែងមានការកេងប្រវ័ញ្ចដើម្បីបង្ខិតបង្ខំឲ្យសុំទាននិងធ្វើសកម្មភាពល្មើសច្បាប់ ដូចជាការដាំដុះវត្ថុញៀណឬការនាំយកវត្ថុញៀណដោយបង្កប់ក្នុងខ្លួន។ ហួសពីការប្រជុំយប្រថានក្នុងការដែលគេរកឃើញនិងផ្តន្ទាទោសក្នុងបទល្មើសទាក់ទងគ្រឿងញៀណ អ្នកដែលគេជួញដូរដើម្បីឲ្យដាំដុះវត្ថុញៀណឬនាំយកដោយដាក់ក្នុងពោះជួបប្រទះនឹងហានិភ័យខ្ពស់ប៉ះពាល់ដល់ជីវិតនិងសុវត្ថិភាព។[21]

### តម្រុយ: ផ្តល់សញ្ញាអំពីទម្រង់ទាំងឡាយនៃការកេងប្រវ័ញ្ច

រដ្ឋទាំងឡាយគួរពិចារណាផ្តល់ដល់អាជ្ញាធរនានានូវសញ្ញានៃការជួញដូរឲ្យលំអិតនិងចំៗដើម្បីឲ្យអ្នកឆ្លើយជាលើកទីមួយ  ស្គាល់ទម្រង់ទាំងឡាយនៃការកេងប្រវ័ញ្ច។ ក្នុងពេលផ្តល់ជំនួយនិងការការពារ ភស្តុតាងសម្រាប់ចំណុចផ្សេងៗទៀតដែលមានចែងក្នុងនិយមន័យអាចឃើញកាន់តែច្បាស់។ ផ្នែក3.3 ផ្តល់មូលដ្ឋានសម្រាប់បង្កើតសញ្ញាដែលមានន័យចំៗនិងលំអិត។

[20] ចំពោះពត៌មានបន្ថែមអំពីការជួញដូរសម្រាប់គោលបំណងយកសរីរាង្គចេញ ចូរមើលដូចជា សេចក្តីណែនាំជាគោលការណ៍របស់អង្គការសុខភាពពិភពលោកអំពីកោសិកាមនុស្ស ជាលិកា និងការប្តូរសរីរាង្គ ( the WHO Guiding Principles on Human Cell, Tissue and Organ Transplantation ) និងសេចក្តីប្រកាសនៃក្រុងអ៊ីស្តានប៊ុល ( the Declaration of Istanbul ), ទាំងពីរមាននៅ  http://www.who.int/transplantation/en/.

[21] ទម្រង់ទាំងពីរនេះត្រូវបានទទួលស្គាល់យ៉ាងច្បាស់លាស់ក្នុងសេចក្តីបង្គាប់របស់សហភាពអឺរ៉ុបស្តីអំពីការជួញដូរ 2011/36/EU ( European Union Trafficking Directive 2011/36/EU  ) ដោយពាក្យ 'ការសុំទានដោយបង្ខិតបង្ខំ' ( forced begging ) មាននិយមន័យថាជាទម្រង់មួយនៃពលកម្មដោយបង្ខិតបងខំឬសេវាដូចដែលផ្តល់និយមន័យដោយ អនុសញ្ញានៃពលកម្មដោយបង្ខិតបង្ខំរបស់អង្គការពលកម្មអន្តរជាតិ ( ILO Forced Labour Convention ) និងការកេងប្រវ័ញ្ចពីសកម្មភាពឧក្រិដ្ឋកម្មត្រូវគេយល់ថាមានរាប់បញ្ចូលអំពើឆក់ លួចឥវ៉ាន់ពីហាង រត់គ្រឿងញៀណ ហើយនិងសកម្មភាពប្រហាក់ប្រហែលដទៃទៀតដែលត្រូវទទួលពិន័យហើយនិងចំណេញប្រាក់។ ចូរមើលសេចក្តីបង្គាប់ 2011/36/EU នៃសភាអឺរ៉ុប និងនៃក្រុមប្រឹក្សានៃសភាអឺរ៉ុប ថ្ងៃទី ៥ មេសា ឆ្នាំ២០១១ ស្តីអំពីការទប់ស្កាត់និងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនិងការការពារជនរងគ្រោះរបស់វា ហើយនិងជំនួសការអនុមត្តអំពីគំរោងរបស់ក្រុមប្រឹក្សាលេខ 2002/629/JHA, OJ L 101/1 ( Council Framework Decision 2002/629/JHA, OJ L 101/1 ), ថ្ងៃទី ១៥មេសា ឆ្នាំ២០១១ សេចក្តីបង្គាប់របស់សហភាពអឺរ៉ុបស្តីអំពីការជួញដូរ 2011/36/EU  ( EU Trafficking Directive 2011/36/EU ) ប្រការ ២( ៣ )

# ផ្នែកទី ២

## កាតព្វកិច្ច ផលប្រយោជន៍ និងឧបសគ្គ

## ២.១. ហេតុអ្វីបានជាការសំគាល់សំខាន់

បើគ្មានការសំគាល់ជនរងគ្រោះទេ រដ្ឋមិនអាចបំពេញគោលដៅនៃការទប់ស្កាត់ ផ្តន្ទាទោស និងការពារដែលមានចែងក្នុងពិធីការនៃការជួញដូរមនុស្សឡើយ។ ដូច្នេះហើយក្នុងការបង្កើតឲ្យបានសព្វជ្រុងជ្រោយនូវគោលនយោបាយប្រឆាំងនឹងការជួញដូរ និងកម្មវិធីពាក់ព័ន្ធនានា គេត្រូវផ្តោតអារម្មណ៍ពិសេសចំពោះការសំគាល់ជនរងគ្រោះថាជាផ្នែកចាំបាច់ក្នុងការបំពេញកាតព្វកិច្ចចែងក្នុងពិធីការនោះ។
វិធីសំគាល់នាំឲ្យដឹងស្ថានភាពរបស់ជនរងគ្រោះ រួចដោយហេតុនេះហើយនឹងមានការផ្តល់ជំនួយនិងសេវាការពារទាន់ពេលដូចជាសេវាសុខាភិបាល ផ្ទះនៅ ម្ហូបអាហារនិងសេចក្តីត្រូវការចាំបាច់ឯទៀតៗ ការពិគ្រោះនិងផ្តល់យោបល់ និងការជួយផ្នែកខាងផ្លូវចិត្ត ។ល។ ក្នុងរដ្ឋខ្លះការបញ្ជាក់ថាជាជនរងគ្រោះពីការជួញដូរ ធ្វើឲ្យជននោះទទួលបាននូវផលនិងសេវាថែមមួយចំនួនទៀតដូចជាផ្ទះនៅបណ្តោះអាសន្នឬជាអចិន្ត្រៃ។ ការខកខានមិនសំគាល់ឲ្យឃើញជនរងគ្រោះឲ្យបានឆាប់និងត្រឹមត្រូវ ភាគច្រើនធ្វើឲ្យគេទាំងនោះបន្តទទួលរងការបំពាននិងកេងប្រវ័ញ្ច ហើយមិនបានទទួលសិទ្ធិរបស់គេ រួមទាំងសិទ្ធិក្នុងការទទួលជំនួយនិងការការពារ។ បើ ការសំគាល់នេះប្រើពេលកាន់តែយូរ ការស្តារឡើងវិញនិងការបញ្ចូលគេទៅក្នុងសង្គមកាន់តែមានភាពស្មុគ្រស្មាញ។ ដោយហេតុនេះហើយ ការសំគាល់ជនរងគ្រោះជាវិធីចាំបាច់ដំបូងមុននឹងឈានទៅដល់ការការពារ។22

លើសពីការការពារជនរងគ្រោះពីការជួញដូរ រដ្ឋក៏មានផលប្រយោជន៍មួយចំនួនទៀតក្នុងការសំគាល់ជនរងគ្រោះពីការជួញដូរ។ ការសំគាល់ជនរងគ្រោះជាយាន្តមួយចំបងក្នុងការស្វែងរកឧក្រិដ្ឋកម្មនិងបណ្តាញនានាពីខាងក្រោយរបស់វា។ ពេលណាជនរងគ្រោះត្រូវបានសំគាល់ហើយ ហើយគេទាំងនោះទទួលបានការការពារនិងការគាំទ្រ គេទាំងនោះអាចក្លាយជាសាក្សីសំខាន់ដែលនឹងជួយក្នុងនីតិវិធីរកយុត្តិធម៌ក្នុងបទឧក្រិដ្ឋទាំងនោះ។ ពេលណាជនរងគ្រោះគ្មានអ្នកណាសំគាល់ឃើញ បណ្តាញឧក្រិដ្ឋកម្មអាចនៅបន្តដោយគ្មានទោសពៃ ហើយភស្តុតាងដ៏មានតម្លៃក៏អាចបាត់។ ឧក្រិដ្ឋកម្មឆ្លងដែនដូចជាការជួញដូរមនុស្ស អាចធ្វើឲ្យឧក្រិដ្ឋកម្មដទៃដូចជាការលាងលុយនិងអំពើពុករលួយរីកដុះដាលនិងបង្អាក់ការលូតលាស់សេដ្ឋកិច្ចនិងសង្គម។ រដ្ឋទាំងឡាយមានផលប្រយោជន៍ក្នុងការទប់ស្កាត់និងដោះស្រាយពលកម្មដោយបង្ខិតបង្ខំ ដែលអាចបណ្តាលឲ្យមានការថយចុះឱកាសមានការងារធ្វើនិងបៀវត្ត ហើយនិងបរិយាកាសការងារក៏ចុះអន់ថយ។ ដូច្នេះហើយការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សជាមធ្យោបាយយ៉ាងសំខាន់មិនគ្រាន់តែសម្រាប់សុវត្ថិភាពនិងសន្តិសុខរបស់បុគ្គលទេ តែក៏សម្រាប់សុខភាពរបស់សង្គម។ 23

**តារាងទី២ : កាតាព្វកិច្ច ផលប្រយោជន៍ និងតម្រុយ សម្រាប់ការសំគាល់ជនរងគ្រោះ**

| កាតព្វកិច្ច | ផលប្រយោជន៍ | តម្រុយ |
|---|---|---|
| **ការទប់ស្កាត់** | ការសំគាល់ជនរងគ្រោះពីការជួញដូរជាការចាំបាច់ក្នុងការទប់ស្កាត់និងការធ្វើឲ្យគេរួញរាក្នុងការជួញដូរមនុស្ស | បញ្ចូលការសំគាល់ជនរងគ្រោះទៅក្នុងយុទ្ធសាស្ត្រជាតិនានារួមទាំងយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងនឹងការជួញដូរនិងឧក្រិដ្ឋកម្មដទៃទៀតដូចជាការរត់ពន្ធទេសន្តរជន និងអំពើហឹង្សាក្នុងគ្រួសារ។ |
| | ការរកឲ្យឃើញមូលហេតុដើមនៃការជួញដូរមនុស្សនិងជនឬក្រុមដែលងាយគេជួញដូរជាការសំខាន់សម្រាប់ការទប់ស្កាត់ដែលសំអាងលើភស្តុតាង | បង្កើតសញ្ញានៃមូលហេតុដើម និងភាពងាយធ្លាក់ចូលរបស់បុគ្គលនិងក្រុមពិសេសទៅក្នុងការជួញដូរ ដើម្បីគាំទ្រការទប់ស្កាត់មុននឹងចូលដល់ដំណាក់ការកេងប្រវ័ញ្ច។ |

[22] ចូរមើល សេចក្តីណែនាំជាគោលនយោបាយស្តីអំពីការការពារជនរងគ្រោះពីការជួញដូរ ( Policy Guide on Protecting Victims of Trafficking ) នីតិវិធីក្រុងបាលី២០១៥ ( Bali Process 2015 ).

[23] ចូរមើល សេចក្តីណែនាំជាគោលនយោបាយស្តីអំពីការការពារជនរងគ្រោះពីការជួញដូរ ( Policy Guide on Protecting Victims of Trafficking ) ផ្នែក ១.១. នីតិវិធីក្រុងបាលី២០១៥ ( Bali Process 2015 ).

| | | |
|---|---|---|
| | ទិន្នន័យនិងពត៌មានទទួលបានដោយអាជ្ញាធរពាក់ព័ន្ធមានភាពរឹងមាំបើវាចេញពីជនរងគ្រោះដែលគេបានសំគាល់ហើយ គឺរួមទាំងទិន្នន័យនិងលក្ខណៈសម្បត្តិរបស់អ្នកជួញដូរ មធ្យោបាយនិងវិធីប្រើ ផ្លូវ និងទំនាក់ទំនងរវាងជនឬក្រុម ហើយនិងវិធានការណ៍ក្នុងការស្រាវជ្រាវរកអ្នកទាំងនោះ។ | ប្រើទិន្នន័យនិងពត៌មានទទួលបានពីក្នុងកម្មវិធីសំគាល់ជនរងគ្រោះ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់រកការខ្វះចន្លោះនៃវិធានការឆ្លើយតបរបស់រដ្ឋចំពោះការជួញដូរមនុស្ស ស្វែងរកសេចក្តីត្រូវការរបស់ភ្នាក់ងាររដ្ឋពាក់ព័ន្ធនានាក្នុងវិស័យបំប៉នសមត្ថភាពនិងបង្ហាត់បង្រៀន ហើយនិងចងក្រងគោលនយោបាយឲ្យកាន់តែប្រសើរក្នុងវិស័យពលកម្មនិងទេសន្តរប្រវេសន៍។ |
| **ការសើបអង្កេតនិងផ្តន្ទាទោស** | ការសើបអង្កេតនិងផ្តន្ទាទោសការជួញដូរមនុស្សនឹងបានរឹងមាំពេលណាអ្នកអនុវត្តទទួលបានការហាត់រៀនឲ្យចេះសំគាល់ជនរងគ្រោះហើយនិងចេះប្រមូលភស្តុតាងពាក់ព័ន្ធ។ | បង្កើតកម្មវិធីបង្ហាត់បង្រៀនរបៀបសំគាល់ជនរងគ្រោះដល់អ្នកនៅជួរមុខ ដូចជាអ្នកសើបអង្កេតនិងរាជអាជ្ញាដើម្បីឲ្យគេ យល់ដឹងដូចគ្នាអំពីផ្នែកទាំងឡាយនៃឧក្រិដ្ឋកម្ម ការប្រមូលភស្តុតាងនិងភាពយកជាបានការឬមិនបានរបស់វា គំរូនានាប្រើក្នុងការសំគាល់ ហើយនិងការយោគយល់ពិសេសដូចជាការធ្វើការជាមួយជនរងគ្រោះឬសាក្សីដែលធ្លាប់ស្លុតរន្ធត់ ជនរងគ្រោះដែលមានវប្បធម៌និងភាសាខុសៗ ជនរងគ្រោះដែលមានវប្បធម៌និងភាសាខុសៗគ្នា ក៏ដូចជាជនរងគ្រោះជាកុមារ។ |
| | អ្នកសើបអង្កេតនិងរាជអាជ្ញាទទួលពត៌មាននិងភស្តុតាងពីជនដែលគេបានបញ្ជាក់ថាជាជនរងគ្រោះពីការជួញដូរហើយ ស្តីអំពីការជួញដូរមនុស្ស អ្នកជួញដូរមនុស្ស ហើយនិងឧក្រិដ្ឋកម្មពាក់ព័ន្ធឬឧក្រិដ្ឋជនដែលអាចមាន។ | បង្កើតប្រព័ន្ធសម្រាប់សំគាល់ជនរងគ្រោះដែលធាប់បានលទ្ធផល គឺប្រើសញ្ញា មួយចំនួនដើម្បីដឹងស្ថានភាពជួញដូរក្នុងស្រុកនិងឆ្លងដែន ហើយនិងប្រភេទខុសគ្នានៃជនរងគ្រោះ( បុរស ស្ត្រី និងកុមារ )ពីការកេងប្រវ័ញ្ចគ្រប់ប្រភេទ។ |
| **ជំនួយនិងការការពារ** | ការសំគាល់ជនរងគ្រោះពីការជួញដូរជាការចាំបាច់សម្រាប់ការផ្តល់សេវាជំនួយនិងការការពារប្រកបដោយប្រសិទ្ធិភាព។ | ផ្តល់ដំណឹងអំពីជនរងគ្រោះទៅភ្នាក់ងារទទួលបន្ទុកដើម្បីផ្តល់ជំនួយនិងការគាំទ្រពិសេស ធ្វើយ៉ាងណាកុំឲ្យជនសន្មតថារងគ្រោះមានឧបសគ្គក្នុងការទទួលជំនួយនិងការការពារ រួមទាំងដោយវិធីបំបែកការសំគាល់ចេញពីវិធីប្រើដោយភ្នាក់ងារអន្តោប្រវេសន៍។ធ្វើយ៉ាងណាឲ្យវិធីសំគាល់ជនរងគ្រោះ អនុវត្ត<br>ចំពោះគ្រប់គ្នាដោយមិនគិតពីអាយុ ភេទ ចំណង់ចំណូលចិត្តក្នុងវិស័យភេទ សញ្ជាតិ ជាតិសាសន៍ ឬឫសគល់សង្គម ឬភាពពិការ ស្របតាមច្បាប់អន្តរជាតិ។ |
| | ជនរងគ្រោះពីការជួញដូរដែលទទួលបានការការពារនិងជំនួយត្រឹមត្រូវ អាចជួយបានល្អជាងក្នុងការរកយុត្តិធម៌ក្នុងរឿងរ៉ាវបទឧក្រិដ្ឋ គឺធ្វើឲ្យមានការផ្តន្ទាទោសអ្នកជួញដូរ ហើយទប់ស្កាត់កុំឲ្យមានការជួញដូរមនុស្សបន្ថែមទៀត។ | ធ្វើយ៉ាងណាឲ្យអ្នកផ្តល់សេវានានាផ្តល់ជំនួយពេញលេញគឺតាំងពីការការពារ ពេលជួបគ្នាលើកដំបូង រហូតដល់ការគាំទ្រក្នុងនីតិវិធីរកយុត្តិធម៌ក្នុងរឿងរ៉ាវបទឧក្រិដ្ឋ ហើយនិងការវិលទៅប្រទេសដើមនិងការរួមរស់ក្នុងសង្គម។ផ្តល់ពត៌មានទៅជនរងគ្រោះអំពីសិទ្ធិរបស់គេក្នុងការទទួលជំនួយនិងការការពារ ហើយនិងជម្រើសទាំងឡាយក្នុងការទទួលការគាំទ្រក្នុងកិច្ចការរកយុត្តិធម៌ប្រឆាំងនឹងអ្នកជួញដូរ និងឲ្យសិទ្ធិទៅគេទាំងនោះក្នុងការសម្រេចចិត្តប្រកបដោយពត៌មានគ្រប់គ្រាន់។ ផ្តល់ការធានាទៅគេថាការសំគាល់( និងការការពារដែលជាលទ្ធផលនៃការសំគាល់ ) មិនពឹងផ្អែកទៅលើការសហការណ៍របស់ជនរងគ្រោះជាមួយអាជ្ញាធរឡើយ។ |
| **ការសហការណ៍** | ការពាក់ព័ន្ធភ្នាក់ងារច្រើនក្នុងការសំគាល់ជនរងគ្រោះ រួមទាំងពត៌មានផ្តល់ឲ្យតាមបែបបទផ្លូវការអំពីសំណាក់អង្គការក្រៅរដ្ឋាភិបាលជំនាញនិងអ្នកដើរតួឯទៀតៗអាចបង្កើនប្រសិទ្ធិភាពរបស់យន្តការនៃការសំគាល់នោះ ដូច្នេះហើយវាក៏ព្រងឹងកម្មវិធីទប់ស្កាត់ ផ្តន្ទាទោសនិងការពារតាមនោះដែរ។. | ធ្វើយ៉ាងណាឲ្យប្រព័ន្ធនៃការសំគាល់ជនរងគ្រោះជាការសហការណ៍រវាងភ្នាក់ងារច្រើន និងជាការសហការណ៍រវាងអាជ្ញាធររដ្ឋនិងអ្នកដើរតួមិនមែនរដ្ឋរួមទាំងអង្គការក្រៅរដ្ឋាភិបាលជំនាញផង។ធ្វើយ៉ាងណាឲ្យមានការផ្តល់ពត៌មានទៅវិញទៅមកជាប្រក្រតីស្តីអំពីទំនោរនៃការជួញដូរក៏ដូចជាបច្ចេកទេសថ្មីៗនិងរបៀបល្អៗក្នុងការសំគាល់ជនរងគ្រោះ។ |

## ២.២. យល់ដឹងថាហេតុអ្វីបានជាជនរងគ្រោះពីការជួញដូរអាចរួញរាក្នុងការបង្ហាញខ្លួនឯង

ជនរងគ្រោះកម្របង្ហាញថាខ្លួនឯងជាជនរងគ្រោះពីការជួញដូរ។ ក្នុងករណីជាច្រើន ជនរងគ្រោះពីការជួញដូរពឹងផ្អែកលើអ្នកជួញដូររបស់គេ ហើយអាចមើលមិនដឹងឬក៏ទទួលថាខ្លួនជាជនរងគ្រោះ។ អ្នកដទៃទៀតឃើញអ្នកជួញដូររបស់គេជាអ្នកមានគុណដែលបានជួយគេបង្កើនស្ថានភាពរបស់គេ។ គេក៏អាចជាប់សាច់ញាតិជាមួយអ្នកជួញដូររបស់គេផងដែរ។ ឧទាហរណ៍ នៅក្នុងបរិបទអាពាពិពាហ៍ដោយបង្ខិតបង្ខំ ឬក៏កុមារត្រូវបានលក់ឲ្យគេកេងប្រវ័ញ្ច ជនល្មើសអាចជាឪពុកម្តាយឬសមាជិកគ្រួសាររបស់ជនរងគ្រោះ ធ្វើឲ្យជនរងគ្រោះរួញរាក្នុងការរាយការណ៍ទៅអាជ្ញាធរ។ អាចដូចគ្នាអញ្ចឹងដែរចំពោះទម្រង់នៃការជួញដូរនិងកេងប្រវ័ញ្ចដទៃទៀត ពេលណាមានទំនាក់ទំនងផ្ទាល់ខ្លួនរវាងជនរងគ្រោះនិងអ្នកជួញដូរ។ ទោះបីពុំមានទំនាក់ទំនងពីមុនក៏ដោយ ជនរងគ្រោះអាចពាក់ព័ន្ធផ្ទាល់ខ្លួនជាមួយអ្នកជួញដូរដោយមិនដឹងថាទំនាក់ទំនងនោះជាយាន្តសម្រាប់គ្រប់គ្រងខ្លួន។

ឧបសគ្គបន្ថែមទៀតក្នុងសំគាល់ជនរងគ្រោះគឺដោយសាររពុំមានផលវង្វាន់ (តាមការយល់ក្នុងចិត្តនិង/ឬការពិត) ក្នុងការប្រាប់ទៅអាជ្ញាធរ។ ចំណុចនេះមានជាពិសេសក្នុងករណីដែលជនរងគ្រោះបានចូលក្នុងប្រទេសមួយដោយមិនប្រក្រតី គឺគេអាចខ្លាចគេបញ្ជូនចេញដោយសារស្ថានភាពរបស់គេមិនប្រក្រតី។ ជនរងគ្រោះដទៃទៀត ទោះបីរងវេទនាយ៉ាងខ្លាំងក្រោមការគ្រប់គ្រងរបស់អ្នកជួញដូរ អាចនៅតែសុខចិត្តនៅក្នុងស្ថានភាពគេកេងប្រវ័ញ្ចនិងបំពាននោះដដែលដោយសារហេតុផលផ្សេងៗ។ ឧទាហរណ៍ ជនរងគ្រោះជាប់ចំណងទំនាក់ទំនងជាមួយអ្នកជួញដូរឬអ្នកដទៃដែលធ្វើឲ្យគេស្ថិតក្នុងស្ថានភាពនោះ ឬក៏គេមានអារម្មណ៍ថាស្ថានភាពដែលគេស្ថិតក្នុងនោះប្រសើរជាងជម្រើសផ្សេងទៀតដែលគេអាចទទួលបាន។ អ្នកជួញដូរឧស្សាហ៍ឆ្លៀតទាញផលចំណេញពីការខ្លាចនិងបារម្ភទាំងនេះដើម្បីគ្រប់គ្រងលើជនរងគ្រោះ។

គេត្រូវយល់និងពិចារណាអំពីបញ្ហាដែលមាននៅក្នុងការសំគាល់ជនរងគ្រោះនៅពេលបង្កើតនិងអនុវត្តយន្តការទាំងឡាយនៃការសំគាល់ជនរងគ្រោះ។ នៅដំណាក់ការណាក៏ដោយ ត្រូវផ្តល់លទ្ធភាពឲ្យមានការបញ្ជូនឈ្មោះមនុស្សទៅក្នុងកម្មវិធីដែលត្រូវស្ថានភាពរបស់គេ ទោះបីគេពុំមានឈ្មោះថាជាជនរងគ្រោះពីដំណាក់មុនៗក៏ដោយ។

### ការបំភិតបំភ័យអំពីការដាក់មន្ទីរឃុំឃាំង និងការបណ្តេញចេញពីប្រទេស

កាលណាជនរងគ្រោះមិនមែនជាពលរដ្ឋក្នុងប្រទេសមួយ  អ្នកជួញដូរឧស្សាហ៍ប្រាប់ជនរងគ្រោះកុំឲ្យរកជំនួយពីអាជ្ញាធរព្រោះគេនឹងចាប់ខ្លួន បញ្ជូនចេញពីប្រទេស ឬឃុំឃាំងដោយសារស្ថានភាពអន្តោប្រវេសន៍របស់ជននោះ ឬដោយសារសកម្មភាពខុសច្បាប់ដែលកើតចេញពីស្ថានភាពជួញដូរ។ ភាគច្រើនចំណុចនេះមិនពិតទេ ហើយបើសិនជាពិត ចំពោះជនរងគ្រោះខ្លះ ការបញ្ជូនចេញពីប្រទេសឬក៏ត្រឡប់ទៅសង្គមវិញ មិនធ្វើឲ្យស្ថានភាពរបស់ជននោះប្រសើរជាងឡើយ។ បើស្ថានភាពដែលបង្កឲ្យមនុស្សម្នាក់ងាយធ្លាក់ក្នុងស្ថានភាពជួញដូរមិនប្រែប្រួលទេ  គេអាចធ្លាក់ចូលក្នុងស្ថានភាពដដែលនោះទៀត។ អ្នកនាំគេចូលក្នុងស្ថានភាពជួញដូរមុននោះអាចនៅដដែល  ធ្វើឲ្យមានការបារម្ភអំពីសន្តិសុខរបស់គេនិងរបស់គ្រួសារគេ។

**តម្រុយ: លើកទឹកចិត្តជនរងគ្រោះឲ្យចេញមកដោយដោះស្រាយបារម្ភរបស់គេ អំពីរឿងឃុំឃាំងនិងរឿងបណ្តេញចេញពីប្រទេស**

ដើម្បីដោះស្រាយការភ័យខ្លាចរបស់ជនរងគ្រោះអំពីការឃុំឃាំង  ត្រូវបង្កើតកម្មវិធីដែលធានាជនរងគ្រោះថាគ្មានទោសពៃទេចំពោះអំពើដែលខ្លួនបានធ្វើដោយសារត្រូវបានគេជួញដូរ រួមទាំងបទល្មើសអន្តោប្រវេសន៍។ ដើម្បីដោះស្រាយការភ័យខ្លាចអំពីការបណ្តេញចេញពីប្រទេស គួរដាក់ឲ្យមានទិដ្ឋាការដែលអនុញ្ញាតិជនរងគ្រោះពីការជួញដូរស្ថិតក្នុងប្រទេសទីដៅដើម្បីទទួលជំនួយនិងការការពារ។

## ការភ័យខ្លាចពីការគំរាមនិងប្រតិកម្មតបពីអ្នកជួញដូរ

ជនរងគ្រោះខ្លះខ្លាចមានការគំរាមនិងប្រតិកម្មតបពីអ្នកជួញដូរពេលណាខ្លួនបង្ហាញប្រាប់គេថាខ្លួនជាជនរងគ្រោះពីការជួញដូរ។ អ្នកជួញដូរឧស្សាហ៍គំរាមថាគេនឹងធ្វើបាបជនរងគ្រោះឬសមាជិកក្រុមគ្រួសាររបស់គេ។ ការខ្លាចអំពីកង្វះខាតប្រព័ន្ធច្បាប់ក្នុងស្រុក ក្នុងការការពារជនរងគ្រោះនិងក្រុមគ្រួសាររបស់គេពីការសងសឹក អាចធ្វើឲ្យជនរងគ្រោះមិនចេញមកជួបគេ។ ការខ្លាចនេះកាន់តែច្រើនបើជនរងគ្រោះមានសមាជិកក្រុមគ្រួសាររស់នៅក្នុងប្រទេសគ្រប់គ្រងដោយច្បាប់ផ្សេង ហើយត្រូវមានអ្នកច្បាប់ពីប្រទេសខុសគ្នាជួយទើបធានាការពារបាន។

### តម្រុយ: លើកទឹកចិត្តជនរងគ្រោះឲ្យចេញមកដោយការពារគេនិងក្រុមគ្រួសារគេ

រដ្ឋគួរពិចារណាបង្កើតកម្មវិធីផ្តល់ការការពារប្រកបដោយប្រសិទ្ធិភាពដល់ជនរងគ្រោះសាក្សីនិងក្រុមគ្រួសាររបស់គេ។ បើមនុស្សដែលត្រូវការការពារស្ថិតនៅរដ្ឋផ្សេង ត្រូវរកការសហការជាមួយអ្នកធ្វើកិច្ចការរកយុត្តិធម៌ក្នុងបទឧក្រិដ្ឋក្នុងរដ្ឋនោះ ឬមួយក៏បើសមស្រប ផ្តល់ទិដ្ឋាការនិងផ្លូវអន្តោប្រវេសន៍ដើម្បីផ្តល់ការការពារដល់ជនដែលអាចមានគ្រោះថ្នាក់។

## អារម្មណ៍អាមាសនិងការខ្លាចមានឈ្មោះអាស្រូវ

បើកម្មវិធីជំនួយនិងការការពារជនរងគ្រោះពុំការពារអត្តសញ្ញាណ ភាពសម្ងាត់ និងរឿងផ្ទាល់ខ្លួនរបស់ជនរងគ្រោះទេ ជនរងគ្រោះអាចខ្លាចថាការឲ្យគេដឹងអាចនាំទៅឲ្យមានការអាមាស ឈ្មោះអាស្រូវនិងការដែលសង្គមមិនរាប់រក។ ជនរងគ្រោះអាចខ្លាចថាបើគេទទួលថាគេបានទទួលរងគ្រោះ ក្រុមគ្រួសារនិងសង្គមរបស់គេអាចមានអារម្មណ៍ថាគេបរាជ័យ (ជាពិសេសបើជនរងគ្រោះត្រូវបានគេកេងប្រវ័ញ្ចតាមផ្លូវធ្វើដំណើរទៅប្រទេសថ្មីនោះ) ដែលបន្ទាប់មកបង្កឲ្យមានការខូចខាតដល់សមត្ថភាពរបស់គេក្នុងការរកចិញ្ចឹមគ្រួសារ។ ជនរងគ្រោះពីការជួញដូរជាបុរស ត្រូវគេបានដឹងថាពិបាកណាស់ក្នុងការទទួលថាគេបានចាញ់បោកគេ។

### តម្រុយ : លើកទឹកចិត្តជនរងគ្រោះឲ្យចេញមកដោយការពារមិនឲ្យមានឈ្មោះអាស្រូវ

រដ្ឋគួរធ្វើយ៉ាងណាឲ្យជំនួយនិងការការពារមានគិតគូរអំពីការខ្លាចរបស់ជនរងគ្រោះចំពោះភាពអាមាសនិងឈ្មោះអាស្រូវដោយរក្សាភាពសម្ងាត់របស់ព័ត៌មានរបស់ជនរងគ្រោះនិងដោយធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលសហគមន៍និងជនរងគ្រោះផ្ទាល់ដើម្បីយល់និងដោះស្រាយបារម្ភនានា ក្នុងការបង្កើតគោលនយោបាយការពារ។

# ផ្នែកទី៣:

## វិធីសំគាល់ជនរងគ្រោះ

### ៣.១. អ្នកណាអាចសំគាល់ជនរងគ្រោះពីការជួញដូរ ?

ការសំគាល់ជនរងគ្រោះកម្របានលទ្ធផលច្បាស់ កើតឡើងក្នុងចំណុចពេលមួយ ប៉ុន្តែវាជាវិធីដែលអាចត្រូវមានដំណាក់ដូចតទៅ ៖

1. ការស្រង់ឈ្មោះដំបូងដែលអាចស្មើថាជាជនរងគ្រោះពីការជួញដូរ។ នេះអាចធ្វើឡើងដោយអ្នកណាម្នាក់ដែលជួបជនសន្មតថាជាជនរងគ្រោះពីការជួញដូរ ហើយលទ្ធផលគឺបញ្ជូនឈ្មោះទៅអាជ្ញាធរពាក់ព័ន្ធ។.
2. ការសន្មតពីអាជ្ញាធរមានសមត្ថកិច្ចថាមានសញ្ញាគ្រប់គ្រាន់ដែលស្មើថាអាចជាជនរងគ្រោះពីការជួញដូរ ហើយគួរទទួលជំនួយនិងការការពារ។
3. ការផ្ទៀងផ្ទាត់ដោយអាជ្ញាធរមានសមត្ថកិច្ចថាជននោះជាជនរងគ្រោះពីការជួញដូរ។ នេះអាចធ្វើឲ្យជននោះត្រូវទទួលបានជំនួយនិងការការពារពេញលក្ខណៈ។ ពេលនោះអាចដំណាលគ្នានឹងការស៊ើបអង្កេតនិងការផ្តន្ទាទោសអ្នកជួញដូរ។
4. ការបញ្ជាក់ថាជននោះជាជនរងគ្រោះពីឧក្រិដ្ឋកម្មនៃការជួញដូរមនុស្ស តាមលទ្ធផលនៃការកាត់ទោសអ្នកជួញដូរ។ ដំណាក់នេះ អាចមានតែក្នុងដែនសមត្ថកិច្ចខ្លះប៉ុណ្ណោះ ហើយការដែលគេមិនអាចកាត់ទោសឧក្រិដ្ឋកម្មនៃការជួញដូរមនុស្សបានដោយជោគជ័យមិនមែនមានន័យថាជនម្នាក់មិនមែនជាជនរងគ្រោះនោះទេ។

ការសំគាល់ជនរងគ្រោះអាចធ្វើឡើងដោយសារលទ្ធផលនៃការស៊ើបអង្កេតបន្ទាប់ពីការរាយការណ៍ដោយផ្ទាល់របស់ជនរងគ្រោះ ក្រុមគ្រួសាររបស់គេ ឬអ្នកដទៃ។ ការសំគាល់ជនរងគ្រោះពីការជួញដូរក៏អាចធ្វើឡើងដោយសកម្មដោយសារលទ្ធផលនៃការស៊ើបអង្កេតរបស់ប៉ូលិសឬអ្នកអនុវត្តដទៃ ដូចជាមន្ត្រីទល់ដែននិងពលកម្ម ដែលប្រកបដោយចំណេះនិងសម្ភារៈសំគាល់ជនរងគ្រោះពីការជួញដូរក្នុងកិច្ចការជាតួនាទីរបស់ខ្លួន។ ការបង្កើនកម្លាំងសំគាល់ជនរងគ្រោះដោយសកម្មជាការប្រសើរជាងការពឹងផ្អែកលើការដឹងដោយគេរាយការណ៍។

អ្នកណាក៏ដោយនៅក្នុងសង្គម រួមទាំងបងប្អូន មិត្តភ័ក្ត គូកន អាចដើរតួសំគាល់ជនរងគ្រោះ ជាពិសេសនៅដំណាក់ដំបូង។ អង្គការក្រៅរដ្ឋាភិបាល រួមទាំងអង្គការសង្គមស៊ីវិល មន្ត្រីពេទ្យ សហជីពអ្នកធ្វើការ ហើយនិងភ្នាក់ងារជ្រើសរើសបុគ្គលិក ជាប្រភពពត៌មានយ៉ាងល្អ ហើយអាចដើរតួយ៉ាងសំខាន់ក្នុងការសំគាល់និងការបញ្ជូនឈ្មោះជនរងគ្រោះទៅអាជ្ញាធរពាក់ព័ន្ធ។ ប៉ុន្តែរដ្ឋមានភារកិច្ចចំបងក្នុងកិច្ចការសំគាល់ជនរងគ្រោះ។ អាជ្ញាធរនានារួមទាំងភ្នាក់ងារអនុវត្តច្បាប់( ប៉ូលិស រាជអាជ្ញា មន្ត្រីច្បាប់ មន្ត្រីអន្តោប្រវេសន៍និងគយ ហើយនិងមន្ត្រីអធិការកិច្ចពលកម្ម) អ្នកសង្គមកិច្ច មន្ត្រីរដ្ឋបាលតាមភូមិ ហើយនិងមន្ត្រីស្ថានទូតនិងកុងស៊ុល អាចដើរតួក្នុងការសំគាល់ជនរងគ្រោះពីការជួញដូរ។ នៅក្នុងរដ្ឋជាច្រើន វិធីផ្លូវការនៃការសន្មតផ្ទៀងផ្ទាត់ និងបញ្ជាក់ដោយអាជ្ញាធរពាក់ព័ន្ធ ត្រូវបានគេប្រើដើម្បីកំណត់ថាជាជនរងគ្រោះ ហើយនិងផ្តល់ជំនួយនិងការការពារទៅតាមកម្រិតដែលពិនិត្យឃើញនោះ។ នៅក្នុងរដ្ឋខ្លះវិធីទាំងនេះគេ

> **តម្រុយ:** បង្កើនការយល់ដឹងរបស់សាធារណជនអំពីការជួញដូរមនុស្សដើម្បីបង្កើនការសំគាល់ជនរងគ្រោះ
>
> រដ្ឋនានាគួរបង្កើតនិងគាំទ្រកម្មវិធីបង្កើនការយល់ដឹងរបស់សាធារណជនអំពីស្ថានភាពនៃការជួញដូរមនុស្ស។ ជាការល្អបំផុតបើកម្មវិធីនោះពន្យល់ចំមនុស្សដែលយើងសំដៅអំពី ៖ក អ្វីទៅជាការជួញដូរមនុស្សនិងតើវាអាចមានរូបរាងដូចម្តេច។
> ខ សកម្មភាពជាក់លាក់ដែលមនុស្សម្នាក់ៗអាចធ្វើ ជាពិសេសទាក់ទងនឹងការផ្តល់ពត៌មានដើម្បីបញ្ជូនទៅអាជ្ញាធរពាក់ព័ន្ធរួមទាំងពត៌មានតាមទូរស័ព្ទហ៉ត់ឡាញ។

[24] អនុសញ្ញាទីក្រុងវីយែណានាឆ្នាំ១៩៦៧បានចែងជាគោលៗអំពីតួនាទី សិទ្ធិនិងការទទួលខុសត្រូវរបស់មន្ត្រីកុងស៊ុលនៅពេលបំពេញភារកិច្ចក្នុងរដ្ឋបញ្ជូននិងរដ្ឋទទួល ដែលក្នុងនោះមួយចំនួនត្រូវនឹងការជួយជនរងគ្រោះពីការជួញដូរ។ សៀវភៅក្បួនសម្រាប់បុគ្គលឹកស្ថានទូតនិងកុងស៊ុលស្តីអំពីវិធីជួយនិងការពារជនរងគ្រោះពីការជួញដូរជាឧបករណ៍មានប្រយោជន៍សម្រាប់បុគ្គលឹកកុងស៊ុល ដោយវាមានចែងសញ្ញាជាក់លាក់មួយចំនួនដែលគេត្រូវដឹងនៅពេលធ្វើការពិនិត្យនិងសម្រេចពាក្យសុំទិដ្ឋាការ។ ចូរមើលសៀវភៅក្បួនសម្រាប់បុគ្គលឹកស្ថានទូតនិងកុងស៊ុលស្តីអំពីវិធីជួយនិងការពារជនរងគ្រោះពីការជួញដូរ លេខាធិការនៃក្រុមប្រឹក្សារដ្ឋសមុទ្របិលទិច ឆ្នាំ២០១១

ប្រគល់ឲ្យទៅមន្ត្រីអនុវត្តច្បាប់ ហើយក្នុងរដ្ឋឯទៀត ទៅភ្នាក់ងាររដ្ឋទទួលបន្ទុកកិច្ចការសង្គមកិច្ច។នៅក្នុងរដ្ឋឯទៀត វិធីជាផ្លូវការក្នុងការសំគាល់ជនរងគ្រោះ ត្រូវបានគេចាត់ឲ្យទៅភ្នាក់ងារមិនមែនរដ្ឋាភិបាលជំនាញមួយចំនួន។ មន្ត្រីកុងស៊ុលក៏អាចដើរតួសំគាល់ជនរងគ្រោះពីការជួញដូរដែរ។

## តម្រុយ: បង្កើនសមត្ថភាពភ្នាក់ងារទាំងឡាយដែលមានតួនាទីសំគាល់

បង្កើតសេចក្តីណែនាំច្បាស់ៗនិងវិធីអនុវត្តដើម្បីពន្យល់តួនាទីនិងភារកិច្ចរបស់អាជ្ញាធរទាំងឡាយនិងអ្នកអនុវត្តពាក់ព័ន្ធឯទៀតៗក្នុងវិធីសំគាល់ជនរងគ្រោះដែលមានប្រសិទ្ធិភាព។.

ទោះបីរដ្ឋអនុវត្តការសំគាល់របៀបណាក៏ដោយ ការបង្ហាត់បង្រៀនសមស្របដល់អង្គភាពពាក់ព័ន្ធជាការសំខាន់ដើម្បីសំគាល់ជនរងគ្រោះពីការជួញដូរឲ្យបានឆាប់និងមានប្រសិទ្ធិភាព។[25] សេចក្តីណែនាំនិងវិធីសំគាល់គួរគោរពនិងការពារសេចក្តីថ្លៃថ្នូរនិងសិទ្ធិមនុស្សរបស់ជនសន្មតថាជាជនរងគ្រោះពីការជួញដូរ។[26]

## តម្រុយ: ផ្តល់ការបង្ហាត់បង្រៀនអំពីការសំគាល់ដល់ជនដែលអាចជួបជនរងគ្រោះពីការជួញដូរ

ការចាត់ឲ្យការបង្ហាត់បង្រៀនធ្វើទៅតាមលំដាប់ថ្នាក់ដល់មន្ត្រីជួរមុខក្នុងការសំគាល់ជនរងគ្រោះជាការសំខាន់។ គេក៏គួរពិចារណាផ្តល់ការបង្ហាត់បង្រៀនដល់គ្រូបង្រៀន អ្នកការសែត មន្ត្រីជំនាញសុខាភិបាល និងអ្នកអនុវត្តក្នុងវិស័យឯកជននិងអ្នកឯទៀតៗក្នុងសហគមន៍ដែលអាចជួបជនរងគ្រោះពីការជួញដូរ ដើម្បីឲ្យគេទាំងនោះស្គាល់សញ្ញាដែលអាចស្មើថាជនម្នាក់ជាជនរងគ្រោះ។

[25] E/2002/68/Add.1), អគ្គស្នងការសហប្រជាជាតិសម្រាប់សិទ្ធិមនុស្ស សេចក្តីណែនាំទី២ : ការសំគាល់ជនត្រូវបានគេជួញដូរនិងអ្នកជួញដូរ សេចក្តីណែនាំទី២(៣)

[26] ចូរមើលផងដែរ សេចក្តីណែនាំជាគោលនយោបាយស្តីអំពីការការពារជនរងគ្រោះពីការជួញដូរ (Policy Guide on Protecting Victims of Trafficking) នីតិវិធីក្រុងបាលី២០១៥ (Bali Process 2015 ), ផ្នែកទី ៣ ស្តីអំពី ការសម្របសម្រួលនិងរបៀបរបបពហុអង្គភាព

## ៣.២. វិធីមូលដ្ឋាន

ដំណាក់និមួយៗនៃវិធីសំគាល់ផ្តល់ឱកាសចម្រាញ់មនុស្សតាមការសង្កេតនិងការប្រាស្រ័យទាក់ទង ចាប់តាំងពីពេលជួបគ្នាដំបូងរហូតដល់ពេលសំភាស។ ក្នុងដំណាក់និមួយៗនៃវិធីសំគាល់សាមញ្ញ អ្នកអនុវត្តត្រូវពិចារណាអំពីតម្រូវការនូវជំនួយនិងការការពាររបស់ជនរងគ្រោះ។[27] រដ្ឋទាំងឡាយគួរពិចារណាបញ្ចូលវិធីសំគាល់ទៅក្នុងវិធីការពារទំទូលាយដើម្បីអនុញ្ញាតិឲ្យការបញ្ជូនឈ្មោះ ទៅកន្លែងសមស្របធ្វើទៅបាននៅពេលគេឃើញថាជនរងគ្រោះត្រូវការការពារពិសេស ( ដូចជាពេលជនរងគ្រោះពីការជួញដូរជាកុមារឬក៏ជាអ្នកសុំសិទ្ធិជ្រកកោន )។

គ្រាជួបគ្នាដំបូង → កិច្ចសម្ភាសន៍ដំបូង → កិច្ចសម្ភាសន៍ជាផ្លូវការ

## ក. ចំណុចជួបគ្នាដំបូង

នៅចំណុចជួបគ្នាដំបូង គោលដៅចំបងគឺពិចារណាថាតើមនុស្សម្នាក់អាចជាជនរងគ្រោះពីការជួញដូរ និងត្រូវការជំនួយដំបូងនិងការការពារឬទេ។ ការស្រង់ឈ្មោះដំបូងកើតឡើងនៅពេលគេជួបជនសន្មតថារងគ្រោះដំបូងដែលជាលទ្ធផលនៃការសង្កេត ( ការសន្ទនាជាមួយជននោះ អាកប្បកិរិយា រូបរាង្គ ឬកាលៈទេសៈ ) ពត៌មានទទួលបានពីជនទី៣ ឬតាមរយៈការបញ្ជាក់ដោយសម៉ីខ្លួន។ ប៉ុន្តែជនរងគ្រោះពីការជួញដូរអាចមិនប្រកាសដោយខ្លួនឯងទេដូចបានលើកឡើងក្នុងផ្នែក 2.2.។

ការស្រង់ឈ្មោះនៅកន្លែងជួបគ្នាដំបូងអាចមានឧបស័គ្គដោយសារបញ្ហាក្នុងការទំនាក់ទំនងដែលបង្កដោយបញ្ហាភាសានិងវប្បធម៌ ក៏ដូចជាបញ្ហាទាក់ទងនិងភេទ។ ឧបស័គ្គទាំងនេះអាចដោះស្រាយមួយផ្នែកបានដោយធ្វើឲ្យអ្នកដែលអាចជួបជនសន្មតថារង
គ្រោះ មានជំនាញភាសានិងវប្បធម៌ ឬមានចំណេះនិងបំពាក់សម្ភារៈ( ឬអាចរកគេដែលមានចំណេះនោះ ) ដែលឲ្យគេធ្វើការស្រង់ឈ្មោះនៅពេលជួបគ្នាដំបូងបាន។

បើការផ្ទៀងផ្ទាត់ពុំអាចធ្វើទៅបានសម្រេច គួរសន្មតថាជននោះជាជនរងគ្រោះដើម្បីឲ្យគេទួលបានសេវាជំនួយនិងការការពារ។ ពេលជួបជនសន្មតថារងគ្រោះ ជននោះអាចស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ដែលអាចកើតឡើងភ្លាមៗ ឬក៏ត្រូវការការព្យាបាលបន្ទាន់ឬក៏ជំនួយដទៃទៀត។ ការធ្វើយ៉ាងណាឲ្យគេមានសុវត្ថិភាពភ្លាមជាអាទិភាពចំបងនៅពេលជួបគ្នាដំបូង។[28] គេត្រូវបញ្ជូនឈ្មោះជនសន្មតថារងគ្រោះឲ្យទៅជួបអ្នកផ្តល់សេវាជំនាញដើម្បីទទួលការថែទាំក្នុងវិស័យសង្គម សុខាភិបាល

---

[27] បន្ថែមទៅលើពត៌មានខាងក្រោម មានពត៌មានថែមទៀតអំពីជនរងគ្រោះពីការជួញដូរក្នុង សេចក្តីណែនាំជាគោលនយោបាយស្តីអំពីការការពារជនរងគ្រោះពីការជួញដូរ ( Policy Guide on Protecting Victims of Trafficking )

[28] ចូរមើល កូនសៀវភៅស្តីអំពីជំនួយផ្ទាល់ចំពោះជនរងគ្រោះពីការជួញដូរ អង្គការទេសន្តរប្រវេសន៍អន្តរជាតិ ឆ្នាំ២០០៥ ( The IOM Handbook on Direct Assistance for Victims of Trafficking, IOM, 2005. )

[29] ចូរមើល សេចក្តីណែនាំជាគោលនយោបាយស្តីអំពីការការពារជនរងគ្រោះពីការជួញដូរ ( Policy Guide on Protecting Victims of Trafficking, ) នីតិវិធីក្រុងបាលីឆ្នាំ២០១៥ ( Bali Process, 2015 )

និងផ្លូវចិត្ត ហើយនិងកន្លែងស្នាក់នៅដើម្បីធ្វើយ៉ាងណាកុំឲ្យគេមានគ្រោះថ្នាក់បន្ថែមទៀត។ វាជាការសំខាន់បំផុតដែរដែលព ត៌មានសម្ងាត់របស់គេត្រូវបានរក្សា ហើយនិងគេផ្តល់ការឯកភាពទទួលយកជំនួយនិងការការពារនានាបន្ទាប់ពីទទួលការព ន្យល់ឲ្យយល់អស់ហើយ។[29]

## តម្រុយ : ពង្រឹងការសំគាល់កុមាររងគ្រោះពីការជួញដូរ

អនុវត្តវិធីដែលបញ្ជាក់បានឆាប់ជាមួយកុមារដែលអាចជាកុមាររងគ្រោះពីការជួញដូរ ហើយនិងផ្តល់ដំណឹងភ្លាមទៅអ្នកផ្តល់សេវាជំនាញសម្រាប់កុមារ តាមរយៈវិធីសំគាល់ដែលទទួលចំណុចទាំង២ខាងក្រោមនេះបាន ៖

- ការសន្មតថាជាកុមារ និង
- ការសន្មតថាជាជនរងគ្រោះ

### ខ. កិច្ចសម្ភាសន៍លើកដំបូង

នៅក្នុងកិច្ចសម្ភាសន៍ដំបូង អាជ្ញាធរអាចបញ្ជាក់ថាមនុស្សម្នាក់ជាជនរងគ្រោះដោយការសន្មត។ គោលបំណងដ៏សំខាន់មួយរបស់កិច្ចសម្ភាសន៍លើកដំបូងគឺការប៉ាន់ស្មានទំហំហានិភ័យហើយនិងគណនាអំពីជំនួយនិងការការពារដែលត្រូវការ។ ក្នុងដំណាក់សម្ភាសន៍លើកដំបូង គេត្រូវប្រាប់ទៅអ្នកដែលគេសម្ភាសនោះអំពីគោលបំណង បែបបទ ហើយនិងផលវិបាកនៃកិច្ចសម្ភាសន៍។ គេគួរផ្តល់ពត៌មានច្បាស់ៗដោយប្រើភាសាដែលអ្នកនោះយល់ ហើយបើចាំបាច់ ប្រើអ្នកបកប្រែដែលមានបទពិសោធន៍។អ្នកសម្ភាសគួរបានហាត់រៀនត្រឹមត្រូវដើម្បីបង្កឲ្យមានសេចក្តីទុកចិត្តហើយនិងការយល់គ្នាជាមួយនឹងជនសន្មតថារងគ្រោះ ហើយនិងបង្កើតបរិយាកាសដែលធ្វើឲ្យជននោះស្រួលចិត្តអាចនិយាយបាន។ ជាការល្អបើអ្នកសម្ភាសបានហាត់រៀនឲ្យយល់អំពីភាពស្លុតរន្ធត់និងចេះជៀសវាងការរំលឹកឲ្យមនុស្សស្លុតរន្ធត់ឡើងវិញ។ អ្នកធ្វើការក្នុងសង្គមស៊ីវិលអាចមានទេព្យកោសល្យជួយក្នុងការធ្វើការជាមួយជនរងគ្រោះពីការជួញដូរនិងអាជ្ញាធរដើម្បីបណ្តុះការទុកចិត្តនិងការនិយាយយល់គ្នា។[31] រដ្ឋខ្លះ ប្រើតារាងសំនួរមានស្រាប់ដើម្បីធ្វើជាលំនាំក្នុងការសម្ភាសដំបូង។ អ្នកសម្ភាសក៏ត្រូវមានជំនាញដើម្បីដោះស្រាយឧបសគ្គបង្កដោយការប្រើភាសាខុសគ្នានិងវប្បធម៌ខុសគ្នា ហើយនិងចេះប្រើបច្ចេកទេសសម្ភាសសមស្របទៅនឹងលក្ខណៈសម្បត្តិរបស់ជននិមួយៗដែលត្រូវសំភាស។

- ទាក់ទងជាមួយនឹងភាសា: អ្នកសំភាសនឹងមានជំនួយពីអ្នកបកប្រែមួយចំនួនដែលអាចហៅបានក្នុងរយៈពេលខ្លី គឺមា នការយល់អំពីផលប៉ះពាល់ពីភាពខុសគ្នាក្នុងភាសា ជាតិសាសន៍និងវប្បធម៌ ដើម្បីបណ្តុះភាពទុកចិត្ត និងការនិយាយយល់គ្នា។ អ្នកបកប្រែគួរមិនលំអៀង ត្រូវបានគេពន្យល់ច្បាស់អំពីតួនាទីរបស់ខ្លួន អំពីការរក្សាភាពសម្ងាត់ និងអំពីអ្វីៗផ្សេងទៀត ហើយត្រូវទទួលបានការហ្វឹកហាត់សមស្រប។ គេក៏ត្រូវពន្យល់ប្រាប់ជនសន្មតថារងគ្រោះអំពីតួនាទីរបស់អ្នកបកប្រែផងដែរ។

- ទាក់ទងជាមួយនឹងភេទនិងអាយុ : ភាគច្រើនវាប្រសើរជាងបើការសម្ភាសធ្វើឡើងដោយអ្នកដែលមានភេទដូចគ្នា ឬក៏មានអ្នកដែលមានភេទដូចគ្នានៅជាមួយ។ កុមារ (ឬអ្នកដែលអាចជាកុមារ) គួរតែចាត់ឲ្យមានអ្នកអាណាព្យាបាលដែលសមស្រប (ឧទាហរណ៍ បើគេគ្មានអ្នកណានៅអម) ហើយត្រូវធ្វើសម្ភាសដោយតែអ្នកដែលបានហាត់ហ្វឹកធ្វើការជាមួយកុមារ។

[30] សេចក្តីណែនាំច្បាប់, ការជួញដូរ, កថាខ័ណ្ឌ ៦៥; សេចក្តីណែនាំរបស់អង្គការ UNICEF ស្តីអំពីភាពយុត្តិធម៌ក្នុងកិច្ចការទាក់ទងនឹងជនរងគ្រោះនិងសាក្សីជាកុមារ (UNICEF Guidelines on the Protection of Child Victims of Trafficking,) និងការបញ្ចេញញមតិចំពោះគោលការណ៍និងសេចក្តីណែនាំរបស់ OHCHR ស្តីអំពីសិទ្ធិមនុស្សនិងការជួញដូរមនុស្ស ឆ្នាំ២០១០ (Commentary to the OHCHR Principles and Guidelines on Human Rights and Human Trafficking, OHCHR, 2010) ទំព័រ ១៦២-១៦៤

[31] ឧទាហរណ៍ គោលការណ៍ណែនាំប្រចាំតំបន់ស្តីអំពីយន្តការសំគាល់គ្រួសៗដំបូងនិងការបញ្ជូនឈ្មោះសម្រាប់ទេសន្តរជនក្នុងស្ថានភាពងាយទទួលរងគ្រោះ (ធ្វើការបង្ហាញដោយ កុស្តារីកា រៀបចំរួមគ្នាដោយ អិលសាលវ៉ាឌ័រ គ្វ័រតេម៉ាឡា ហុនឌូរ៉ាស និង និការ៉ាគ្វ ដោយមានជំនួយពី IOM និងអគ្គស្នងការអង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួន ធ្វើការបង្ហាញជូនក្រុមពិគ្រោះប្រចាំដំបន់អំពីទេសន្តរប្រវេសន៍ ខែ មិថុនា ២០១២ ទំព័រ

- **ទាក់ទងនឹងវប្បធម៌** : វាអាចជាការប្រសើរឬមិនប្រសើរដែលអ្នកសម្ភាសចេញពីសង្គមឬក៏មានវប្បធម៌ដូចអ្នកដែលគេសម្ភាសដែរ។ ទោះបីអ្នកដែលគេសម្ភាសអាចមានអារម្មណ៍ល្អជាមួយអ្នកដែលមានវប្បធម៌ដូចគ្នា  ក្នុងករណីដែលសហគមន៍នោះមានការពាក់ព័ន្ធឬក៏ខ្លាចមិនហ៊ាននិយាយអំពីការកេងប្រវ័ញ្ចនោះ  អ្នកដែលគេសម្ភាសអាចស្ថិតក្នុងគ្រោះថ្នាក់ធំបើអ្នកសម្ភាសចេញមកពីសហគមន៍របស់ខ្លួនដែរ។

ការគិតពិចារណាថាធ្វើយ៉ាងណាសមរម្យសម្រាប់កិច្ចសម្ភាសន៍មួយត្រូវការការពិគ្រោះជាមួយអ្នកដែលគេសម្ភាសថាតើគេប្រាថ្នាអ្វីខ្លះ ហើយធ្វើតាមអ្វីដែលគេចង់បានតាមដែលអាចធ្វើបាននិងសមស្រប។

**តម្រុយ:** គាំទ្របច្ចេកទេសសម្ភាសដែលសមស្របតាមលក្ខណៈសម្បត្តិរបស់ជនរងគ្រោះ

ធ្វើយ៉ាងណាឲ្យអ្នកសម្ភាសមានជំនាញទប់ទល់នឹងបញ្ហាក្នុងវិស័យភាសាភេទអាយុនិងវប្បធម៌។តាមដែលអាចធ្វើបាន ពិគ្រោះជាមួយអ្នកដែលត្រូវគេសម្ភាសនិមួយៗអំពីអ្វីដែលគេប្រាថ្នា ហើយបំពេញបំណងគេតាមសមស្រប។

ក្នុងការសម្ភាសដំបូង មានចំណុចសំខាន់ខ្លះដែលត្រូវគិតទោះបីជននោះមានលក្ខណៈសម្បត្តិឬស្ថិតក្នុងឋានៈណាក៏ដោយ។ ឧទាហរណ៍ វាជាការប្រសើរបើកម្មវិធីសំគាល់មានបញ្ចូលកម្មវិធីទទួលនិងពិចារណាលើការសុំសិទ្ធិជ្រកកោនអំពីជនរងគ្រោះពីការជួញដូរដែលអាចត្រូវការសិទ្ធិជ្រកកោន។32 អាជ្ញាធរទទួលបន្ទុកវិស័យសុំសិទ្ធិជ្រកកោន (ឬ UNHCR ក្នុងប្រទេសខ្លះដែលគ្មានប្រព័ន្ធជាតិក្នុងវិស័យសុំសិទ្ធិជ្រកកោន) គួរធ្វើការសម្រេចលើឋានៈជាជនភៀសខ្លួនរបស់ជនទាំងឡាយដែលកាលពីនៅក្នុងដំណាក់វិធីសំគាល់ បានផ្តល់សញ្ញាថាគេអាចស្ថិតក្នុងភាពគ្រោះថ្នាក់អំពីការធ្វើទុក្ខកាប់សម្លាប់ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរក្នុងប្រទេសដើមរបស់ខ្លួន។ ដូចគ្នាផងដែរ អាជ្ញាធរប្រឆាំងនឹងការជួញដូរគួរស្រង់ឈ្មោះជនសុំសិទ្ធិជ្រកកោននិងជនភៀសខ្លួនដែលបង្ហាញសញ្ញាថាគេអាចជាជនរងគ្រោះពីការជួញដូរ។ គួរមានបង្កើតយន្តការសមស្របសម្រាប់បញ្ជូនឈ្មោះរបស់ជនទាំងឡាយណាដែលប្រាថ្នាសុំការការពារអន្តរជាតិក្នុងនាមជាជនភៀសខ្លួន ទៅអាជ្ញាធរទទួលបន្ទុកវិស័យសុំសិទ្ធិជ្រកកោន ហើយនិងសម្រាប់ការបញ្ជូនឈ្មោះជនសុំសិទ្ធិជ្រកកោននិងជនភៀសខ្លួនដែលអាចជួញដូរជនរងគ្រោះ ទៅអាជ្ញាធរប្រឆាំងនឹងការជួញដូរសមស្រប។ ក្នុងករណីទាំងពីរ អាជ្ញាធរគួរធ្វើយ៉ាងណាកុំឲ្យការប្រាស្រ័យទាក់ទងជាមួយនឹងអាជ្ញាធរក្នុងប្រទេសដើមបង្កគ្រោះថ្នាក់ដល់ជនដែលអាចជាជនសុំសិទ្ធិជ្រកកោនឬជនភៀសខ្លួន។

**តម្រុយ:** ចាត់ឲ្យកម្មវិធីសំគាល់មានលទ្ធភាពបញ្ជូនឈ្មោះរបស់ជនសុំសិទ្ធិជ្រកកោនទៅអង្គភាពនានាសមស្រប

រដ្ឋទាំងឡាយមិនគួរទាក់ទងភ្នាក់ងារស្ថានទូតរបស់ប្រទេសដើមដើម្បីធ្វើការសំគាល់ឡើយ បើជនម្នាក់បានដាក់ពាក្យសុំសិទ្ធិជ្រកកោន ឬក៏បើមានហេតុផលថាជននោះជាជនភៀសខ្លួន។

## គ. កិច្ចសម្ភាសន៍ជាផ្លូវការ

កិច្ចសម្ភាសន៍ជាផ្លូវការផ្តល់ឱកាសឲ្យគេពិនិត្យលំអិតនូវជំនួយនិងការការពារដែលបានផ្តល់ហើយដោយសំអាងលើសេចក្តីត្រូវការទាំងឡាយដែលបានពិនិត្យឃើញ។ ជាទម្លាប់ប្រសើរបំផុតគឺអាជ្ញាធរផ្តល់ដល់ជនរងគ្រោះនូវ "ឱកាសពិចារណា" ដើម្បីជួយឲ្យគេនឹកឃើញគ្រប់គ្រាន់អំពីភាពទទួលរងវេទនាដើម្បីផ្តល់ភស្តុតាងក្នុងកិច្ចសម្ភាសន៍ជាផ្លូវការ។.33 អាស្រ័យទៅលើសេចក្តីត្រូវការនិងស្ថានភាពរបស់ជនរងគ្រោះឬសន្មតថារងគ្រោះពីការជួញដូរ កិច្ចសម្ភាសន៍ជាផ្លូវការអាចចាប់ផ្តើមមុនឬក្រោយការចាប់ផ្តើមនៃ"ឱកាសពិចារណា" ក្នុងចំណុចពេលមួយដែលជនដែលអាចរងគ្រោះនោះមានលទ្ធភាពផ្តល់ពត៌មានបានល្អបន្ទាប់បានទទួលជំនួយនិងការការពារហើយ។

32 ចូរមើលប្រការ ១៤ នៃពិធីការជួញដូរមនុស្ស។ ចូរមើលផងដែរ គោលការណ៍ដែលគួរមាននិងសេចក្តីណែនាំស្តីអំពីសិទ្ធិមនុស្សនិងការជួញដូរមនុស្ស (Recommended Principles and Guidelines on Human Rights and Human Trafficking) (E/2002/68/Add.1), អគ្គស្នងការអង្គការសហប្រជាជាតិសម្រាប់សិទ្ធិមនុស្ស សេចក្តីណែនាំ ២(៧)

33 ចំពោះពត៌មានថែមទៀតអំពីឱកាសពិចារណា ចូរមើលសេចក្តីណែនាំជាគោលនយោបាយស្តីអំពីការការពារជនរងគ្រោះពីការជួញដូរ ឆ្នាំ២០១៥ (Policy Guide on Protecting Victims of Trafficking, Bali Process, 2015)

ពេលណាជំនួយនិងការការពារត្រូវបានផ្តល់ហើយ អាចធ្វើកិច្ចសម្ភាសន៍បន្ថែមទៀតសម្រាប់គោលបំណងស៊ើបអង្កេតនឹង ផ្តន្ទាទោស។ ពត៌មានអាចរកប្រមូលដើម្បីបញ្ជាក់ថាជនម្នាក់ជាជនរងគ្រោះពីការជួញដូរឬមិនមែន។ គេត្រូវឯកភាពក្នុងការសម្ភាស ការថតទុកជារូបភាពឬសម្លេង ហើយនិងយល់អំពីគោលបំណងនិងផលវិបាកនៃកិច្ចសម្ភាសន៍។[34] កិច្ចសម្ភាសន៍និងសេចក្តីកត់ត្រាជាលាយលក្ខណ៍អក្សរឬការថតទុកគួររក្សាជាសម្ងាត់ដើម្បីការពារជនដែលគេសម្ភាសនិងពត៌មានរបស់គេ។ អ្នកសម្ភាសគួរមានការហាត់ហ្វឹកពិសេសដើម្បីយល់ហេតុអ្វីរឿងរ៉ាវរបស់ជនរងគ្រោះអាចដូរ ហើយនិងគួរសំាំនិងការធ្វើការជាមួយមនុស្សដែលមានអាយុខុសៗគ្នា និយាយភាសាខុសៗគ្នា មានវប្បធម៌ខុសៗគ្នា ហើយនិងអាចស្លុតរន្ធត់។ [35]

ដំណាក់កាលនេះអាចចេញលទ្ធផលជាពាក្យថ្លែងរបស់ជនរងគ្រោះ។ ក្នុងដំណាក់កាលនេះគួរប្រមូលពត៌មានដទៃទៀតដើម្បីផ្ទៀងបញ្ជាក់ពាក្យរបស់ជនរងគ្រោះ។ កម្មវិធីការពារដែលបានដាក់អនុវត្តសម្រាប់បុគ្គលម្នាក់អាចត្រូវធ្វើការសើរើកែប្រែដោយផ្អែកលើពត៌មានទទួលបានក្នុងកិច្ចសម្ភាសន៍។ អាចត្រូវការបញ្ជូនឈ្មោះទៅឲ្យភ្នាក់ងារផ្តល់សេវាជំនាញមួយចំនួន។

ដូចបានលើកឡើងខាងលើក្នុងផ្នែក 2.2 ជនរងគ្រោះអាចរួញរាក្នុងការទុកចិត្តអាជ្ញាធរ។ ការធ្វើការសម្ភាសជាមួយជនរងគ្រោះអាចជួបការលំបាក ហើយត្រូវការការយល់និងការអត់ធ្មត់ដើម្បីជៀសវាងការបង្កឲ្យមានសម្ពាធនិងភាពរំជើបរំជួលចិត្តដល់ជនរងគ្រោះបន្ថែមទៀត។ អ្នកសម្ភាសគួរផ្តោតលើការបង្កឲ្យមានទំនុកចិត្តនិងការជឿជាក់លើខ្លួនឯង។ កន្លែងណាអាចធ្វើបាន អ្នកសម្ភាសគួរជៀសវាងបង្កឲ្យជនរងគ្រោះនឹកឃើញឡើងវិញនូវបទពិសោធន៍ដែលធ្វើឲ្យគេស្លុតរន្ធត់ អាមាសនិង/ឬធ្វើឲ្យគេបាត់អំណាច ឬបាត់ការទុកចិត្តលើខ្លួនឯងក្នុងការសម្រេចចិត្តដែលប្រកបដោយពត៌មានគ្រប់គ្រាន់។ ការមិនជៀសវាង អាចបង្កការខូចខាតថែមទៀតដល់ជនរងគ្រោះ រារាំងការប្រមូលភស្តុតាង ហើយនិងធ្វើឲ្យជនរងគ្រោះពុំមានចិត្តចង់បន្តសហការក្នុងកម្មវិធីរកយុត្តិធម៌ក្នុងបទឧក្រិដ្ឋនោះ។

## ៣.៣. សញ្ញានៃការជួញដូរ

ក្នុងរដ្ឋជាច្រើន គេប្រើសញ្ញាជាស្តង់ដាមួយចំនួនសម្រាប់សំគាល់ស្ថានភាពដែលអាចជាការជួញដូរ។ សញ្ញាទាំងនោះអាចជាឧបករណ៍មានប្រយោជន៍សម្រាប់បង្ហាត់បង្រៀននិងបង្កើនសមត្ថភាពភ្នាក់ងារពាក់ព័ន្ធ( ដូចជាភ្នាក់ងារសុខាភិបាល ប៉ូលិសមន្ត្រីអន្តោប្រវេសន៍និងគយ ) ហើយអាចមានទំនាក់ទំនងនឹងផ្នែកពិសេសនៃការជួញដូរ( ឧទាហរណ៍  មធ្យោបាយដែលអ្នកជួញដូរប្រើក្នុងការតម្រូវឲ្យជនរងគ្រោះធ្វើបំពេញកិច្ចអ្វីមួយ ) ឬក៏ទាក់ទងនឹងប្រភេទពិសេសណាមួយនៃការកេងប្រវ័ញ្ច ( ឧទាហរណ៍ ពលកម្មដោយបង្ខិតបង្ខំ )។ ជាជាក់ស្តែង ដោយសារភាគច្រើនជនរងគ្រោះត្រូវគេរកឃើញនៅពេលគេរងការកេងប្រវ័ញ្ច សញ្ញានានាទាក់ទងនឹងសកម្មភាពក្នុងដំណាក់ការកេងប្រវ័ញ្ចធ្វើឲ្យគេមានទំនុកចិត្តជាង។

### តម្រុយ:  ពិចារណាដាក់កំរិតទម្ងន់ឲ្យសញ្ញា

រដ្ឋនានាគួរពិចារណាដាក់ទម្ងន់ឲ្យសញ្ញាដើម្បីជួយដល់អ្នកទទួលបន្ទុកក្នុងការសំគាល់ជនរងគ្រោះដើម្បីឲ្យពត៌មានប្រភេទខ្លះស្ថិតតាមលំដាប់លេខរៀង។ វិធីដែល ILO និងស្នងការអឺរ៉ុបប្រកាន់យក ធ្វើឲ្យសញ្ញានិមួយៗមានទម្ងន់ធ្ងន់មធ្យមឬស្រាល ដោយមានចែងថាសញ្ញាមួយអាចធ្ងន់សម្រាប់កុមារតែមធ្យមសម្រាប់មនុស្សពេញវ័យ ឬក៏ធ្ងន់សម្រាប់ការកេងប្រវ័ញ្ចផ្លូវភេទ ហើយស្រាលសម្រាប់ការកេងប្រវ័ញ្ចពលកម្ម។

ទោះជាយ៉ាងណា គេត្រូវយល់ជានិច្ចអំពីកង្វះខាតដែលជាធម្មជាតិរបស់សញ្ញា។ ដោយសារមនុស្សត្រូវបានគេជួញដូរតាមវិធីខុសៗគ្នា ហើយនិងកេងប្រវ័ញ្ចក្នុងបរិបទខុសៗគ្នា សញ្ញាខ្លះស្ទើថាជាការជួញដូរខ្លាំងជាងសញ្ញាឯទៀតជានិច្ច។ និយាយម្យ៉ាងទៀតគឺថាក្នុងករណីមួយ សញ្ញាបង្ហាញច្បាស់ក្រឡែតថាជាការជួញដូរ ប៉ុន្តែគ្មានទៅវិញក្នុងករណីមួយទៀត។ ឧទាហរណ៍ មនុស្សម្នាក់ធ្វើការរៀងរាល់ថ្ងៃច្រើនម៉ោងហួសហេតុដោយបានប្រាក់បំណាច់បន្តិចបន្តួចក្រោមការឃាមកាមរបស់អ្នកមានបំពាក់អាវុធ ជាសញ្ញាថាជួញដូរជាងកុ

34 ជាទូទៅកុមារពុំអាចផ្តល់សេចក្តីយល់ព្រតាមលក្ខណៈច្បាប់ទេ។ គេគួររកការឯកភាពពីឪពុកម្តាយឬអ្នកអាណាព្យាបាលឲ្យបានច្បាស់មុននឹងឈានទៅធ្វើការសម្ភាសជាមួយកុមារ។

35 ចូរមើលសៀវភៅក្បួនសម្រាប់អ្នកធ្វើការក្នុងការរកយុត្តិធម៌ក្នុងឧក្រិដកម្ម ស្តីអំពីការប្រឆាំងនិងការជួញដូរមនុស្ស ( Anti-Human Trafficking Manual for Criminal Justice Practitioners ) ភាគ ៨ :ការសម្ភាសជនរងគ្រោះពីការជួញដូរដែលថ្ងៃក្រោយអាចជាសាក្សី UNODC ឆ្នាំ២០០៩ ( Interviewing victims of trafficking who are potential witnesses UNODC 2009 )

មារម្នាក់ដែលគេនាំឆ្លងដែនដោយគ្មានលិខិតឆ្លងដែន។ សញ្ញាខ្លះអាចស្នើថាជាឧក្រិដ្ឋកម្មឬរឿងរ៉ាវប្រភេទផ្សេង ហើយវត្តមានឬអវត្តមាននៃសញ្ញាណាមួយមិនអាចបញ្ជាក់ជាលទ្ធផលថាការជួញដូរមនុស្សបានឬមិនកើតឡើងនោះឡើយ។[36] កង្វះខាតមួយទៀតគឺថាអ្នកជួញដូរបានដូរទៅតាមសញ្ញាហើយអនុវត្តទៅតាមនោះ ដូចជាឲ្យជនរងគ្រោះកាន់អត្តសញ្ញាណប័ណ្ណនិងឯកសារធ្វើដំណើរខ្លួនឯង គឺដើម្បីកុំឲ្យអាជ្ញាធរសង្ស័យ។ ឃើញកង្វះខាតដូច្នេះហើយ ការប្រើសញ្ញាប្រភេទខុសៗគ្នាចម្រុះនឹងធ្វើឲ្យយើងឃើញបានល្អជាងការពឹងលើតែប្រភេទតែមួយ។ ថែមពីលើនេះទៀត សញ្ញាពុំមែនជាការបញ្ជាក់ថាមានការជួញដូរទេ ប៉ុន្តែអាចប្រើដើម្បីពន្យល់ភាពត្រឹមត្រូវរបស់ការសន្និដ្ឋានដែលគាំទ្រជនរងគ្រោះសម្រាប់គោលបំណងទទួលជំនួយនិងការការពារ។

តារាងសញ្ញាគំរូ(ដែលមានពុំសព្វ) ដាក់ជូនខាងក្រោមនេះទន្ទឹមនឹងប្រភេទនៃការកេងប្រវ័ញ្ចខុសៗគ្នាដែលមានចុះក្នុងពិធីការនៃការជួញដូរមនុស្ស ត្រូវមើលដោយមានការចងចាំថាវាមានកង្វះខាតដូចបានរៀបរាប់ខាងលើ។ ដោយសារតារាងនៃការកេងប្រវ័ញ្ចចែងក្នុងពិធីការ(the Protocol)ពុំមានសព្វទាំងអស់ សញ្ញានៃការកេងប្រវ័ញ្ចឯទៀតៗដែលគេចេះតែពើបប្រទះជាក់ស្តែងថែមទៀតនោះក៏មានដាក់ជូនខាងក្រោមនេះដែរ។ ពាក្យថា ជន រៀបរាប់ក្នុងសញ្ញាទាំងឡាយខាងក្រោមនេះគឺសំដៅទៅលើជនសន្មតថារងគ្រោះ គឺមិនមែនជាជនដែលអាចជាអ្នកជួញដូរឡើយ។

## តម្រុយៈ កែសម្រួលសញ្ញាទៅតាមបរិបទ

តារាងសញ្ញាមានប្រសិទ្ធិភាពបំផុតបើគេយកទៅកែប្រើក្នុងស្ថានភាពជាក់ស្តែងដែលអាជ្ញាធរពើបប្រទះក្នុងការងាររបស់ខ្លួន។ បើអាចធ្វើបាន រដ្ឋទាំងឡាយគួរពិនិត្យសើរើតារាងសញ្ញាជាប្រចាំធ្វើឲ្យទាន់សម័យ ដើម្បីធានាឲ្យត្រូវតាមទំនោរនៃការជួញដូរដែលផ្លាស់ប្តូរ។

## សញ្ញាសំខាន់ៗនៃការកេងប្រវ័ញ្ចដែលឧស្សាហ៍ឃើញមាន

សញ្ញាទាំងឡាយខាងក្រោមនេះអាចប្រើសម្រាប់ការកេងប្រវ័ញ្ចក្នុងទ្រង់ទ្រាយណាក៏បាន។ សញ្ញាខ្លះចង្អុលប្រាប់ថាជាសញ្ញានៃការកេងប្រវ័ញ្ច ហើយខ្លះទៀតថាជាសញ្ញានៃការគ្រប់គ្រងរបស់អ្នកជួញដូរទៅលើជនសង្ស័យជាជនរងគ្រោះ។

- ជននោះត្រូវបានគេបង្ខំ/កៀបឲ្យចូលឬបន្តស្ថិតនៅក្នុងស្ថានភាពនោះ។
- ជននោះត្រូវគេបោកបញ្ឆោតអំពីជាតុពិត/ទីកន្លែងនៃស្ថានភាព។
- ចំនួនថ្ងៃឬម៉ោងធ្វើការរបស់ជននោះច្រើនហួសហេតុ
- ស្ថានភាពកន្លែងរស់នៅឬកន្លែងធ្វើការមិនសមសម្រាប់មនុស្សឬធ្វើឲ្យថោកទាប
- ជននោះស្ថិតក្រោមការត្រួតត្រារបស់អ្នកដទៃឬពឹងផ្អែកសឹងតែទាំងស្រុងលើអ្នកដទៃ
- ជននោះរងការគំរាមឬការប្រើហឹង្សា
- ជននោះស្ថិតក្នុងស្ថានភាពមួយដែលមិនសមនឹងអាយុរបស់ខ្លួន

## សញ្ញាសំខាន់ៗនៃការកេងប្រវ័ញ្ចប្រភេទជាក់លាក់

សញ្ញាទាំងឡាយខាងក្រោមនេះទាក់ទងនឹងទម្រង់ជាក់លាក់នៃការកេងប្រវ័ញ្ចដែលមានចែងក្នុងពិធីការនៃការជួញដូរមនុស្ស (Trafficking in Persons Protocol)។ ដោយសារតារាងប្រភេទនៃការកេងប្រវ័ញ្ចក្នុងពិធីការនោះមិនបានរៀបរាប់អស់ប្រភេទ សញ្ញារបស់ប្រភេទនៃការកេងប្រវ័ញ្ចផ្សេងទៀតដែលគេកាន់តែឧស្សាហ៍ជួបប្រទះជាក់ស្តែងក៏មានចុះខាងក្រោមនេះដែរ។

36 ចូរមើល សៀវភៅក្បួនសម្រាប់អ្នកធ្វើការក្នុងការរកយុត្តិធម៌ក្នុងឧក្រិដកម្ម ស្តីអំពីការប្រឆាំងនិងការជួញដូរមនុស្ស UNODC/UN.GIFT, ឆ្នាំ២០០៩ (Anti-human trafficking manual for criminal justice practitioners, UNODC/UN.GIFT, 2009) ភាគ 2. ចូរមើលផងដែរ យន្តការជាតិនៃការបញ្ជូនឈ្មោះ (National Referral Mechanisms) : កូនសៀវភៅសម្រាប់អនុវត្ត OSCE, ឆ្នាំ២០០៤, ទំព័រ៦១

### ការកេងប្រវ័ញ្ចអំពីពេស្យាចាររបស់អ្នកដទៃ និងទ្រង់ទ្រាយនៃការកេងប្រវ័ញ្ចដទៃទៀត

ដូចបានចែងក្នុងតារាង ទី១ (ផ្នែក 1.1) មិនមែនគ្រប់គ្នាដែលធ្វើការក្នុងឧស្សាហកម្មផ្លូវភេទជាជនរងគ្រោះពីការជួញដូរនោះទេ។ សញ្ញាខាងក្រោមនេះអាចមានប្រយោជន៍ក្នុងការបញ្ជាក់ជនទាំងឡាយដែលគេបានសន្មតនោះថាជាជនរងគ្រោះពីការជួញដូរឬមិនមែន។

- ជននោះមិនអាចប្រកែកមិនបំរើភ្ញៀវ ធ្វើក្បាច់ភេទអ្វីមួយចំនួនពិសេស ឬក៏រួមភេទដោយមិនប្រើប្រដាប់ការពារ។
- ជននោះមិនទទួលប្រាក់ផ្ទាល់ពីភ្ញៀវ ឬក៏ទទួលតែមួយភាគតូចពីប្រាក់ដែលភ្ញៀវបង់ឲ្យទៅថៅហ្វាយនាយឬអ្នកនាំ
- ជននោះត្រូវបានបង្ខំឬកៀបឲ្យប្រើឬមិនប្រើថ្នាំឬប្រដាប់ការពារពិសេសកុំឲ្យមានគត៌
- ជននោះត្រូវបានបង្ខំឬកៀបឲ្យទទួលការធ្វើតេសអំពីសុខភាពឬគត៌
- ជននោះក្រោមអាយុ

### ជួញដូរក្នុងគោលបំណងយកសរីរាង្គចេញ

សញ្ញាខាងក្រោមនេះពាក់ព័ន្ធនឹងស្ថានភាពដែលគេនឹងយកចេញឬបានយកចេញសរីរាង្គសម្រាប់ប្តូរក្នុងបរិបទពេទ្យ។ វាមិនសូវត្រូវនឹងការយកសរីរាង្គចេញសម្រាប់គោលបំណងវប្បធម៌ឬពិធីជាជំនឿទេ។

- ជននោះត្រូវគេបង្ខំឬកៀបឲ្យព្រមឲ្យគេយកសរីរាង្គចេញ។
- ជននោះត្រូវគេបោកអំពីរបៀបធ្វើឬប្រាក់ដែលត្រូវទទួលបានពីការយកសរីរាង្គចេញ។
- ជននោះពុំដឹងទីណាឬពេលណាការប្តូរសរីរាង្គនោះនឹងធ្វើឡើងឡើយ
- ជននោះពុំយល់អំពីរបៀបប្តូរសរីរាង្គនិងហានិភ័យពាក់ព័ន្ធ
- ហាក់ដូចជាមានភាគីទីពិញ
- មានសញ្ញាថាអ្នកត្រូវទទួលសរីរាង្គនោះមានបំណងធ្វើដំណើរទៅបរទេសជាមួយជននោះ។

### ជួញដូរសម្រាប់គោលបំណងឲ្យធ្វើសេវកជនក្នុងផ្ទះ

- ជននោះទទួលម្ហូបអាហារដែលមានគុណភាពទាបឬក្រោមស្តង់ដារ ហើយមានសញ្ញាខ្វះជីវជាតិចិញ្ចឹមខ្លួន
- ជននោះធ្វើការរយៈពេលម៉ោងច្រើនហួសហេតុ
- ជននោះពុំមានកន្លែងលំហាឯកជនឬកន្លែងលំហាឯកជននោះមិនគ្រប់គ្រាន់
- ជននោះស្ថិតក្នុងបន្ទប់ឃុំឃាំងឬពុំមានសេរីភាពទាក់ទងសង្គម និង/ឬពុំដែលចេញពីផ្ទះដោយគ្មានថៅហ្វាយនាយ
- ជននោះទទួលរងពាក្យជៀល ជេរប្រមាថ គំរាមកំហែង ហឹង្សា និង/ឬការវាយទាត់
- ជននោះបង់ថ្លៃជ្រើសរើសអ្នករកការធ្វើ
- ជននោះក្រោមអាយុ

### ជួញដូរសម្រាប់គោលបំណងរៀបការដោយបង្ខិតបង្ខំ ដោយមុនពេលកំណត់

- ជំនូនជាប្រាក់ឬវត្ថុផ្សេងទៀតត្រូវបានប្រគល់ទៅឲ្យភាគីទីពក្នុងការធ្វើឲ្យអាពាហ៍ពិពាហ៍នោះកើតឡើង
- កិច្ចសន្យាអាពាហ៍ពិពាហ៍ត្រូវបានចរចារដោយភាគីដែលមិនមែនជាអ្នករៀបការ និង/ឬដោយគ្មានការពាក់ព័ន្ធឬការឯកភាពពីអ្នករៀបការ។
- ជននោះត្រូវបានបង្ខំឲ្យចូលក្នុងស្ថានភាពកេងប្រវ័ញ្ចពលកម្ម ផ្លូវភេទ ឬសម្រាប់នៅតែបំរើក្នុងផ្ទះ
- ជននោះបានធ្វើតេសឬនឹងត្រូវធ្វើតេសព្រហ្មចារី
- បងប្អូនជននោះត្រូវបានគេបង្ខំឲ្យរៀបការ
- ជននោះមានសញ្ញាកើតទុក្ខ បង្ករបួសដល់ខ្លួនឯង នៅដាច់ពីសង្គម ឬប្រើវត្ថុខុស (គ្រឿងញាណ)
- មានសញ្ញាមិនចុះសម្រុងក្នុងគ្រួសារ ហឹង្សា ឬការបំពាន
- ជននោះក្រោមអាយុ

ជួញដូរសម្រាប់កេងប្រវ័ញ្ចក្នុងសកម្មភាពសុំទាន និងឧក្រិដ្ឋកម្មផ្សេងៗ

- ជននោះទទួលទណ្ឌកម្មបើគេសុំឬលួចមិនគ្រប់
- ជននោះរស់នៅជាមួយអ្នកដទៃដែលធ្វើសកម្មភាពដូចគ្នា
- ជននោះមិនយល់ពីគោលបំណងនៃសកម្មភាពរបស់ខ្លួនឬភាពខុសច្បាប់របស់វា។
- ជននោះក្រោមអាយុ ជាមនុស្សជរា ឬពិការ

សញ្ញារៀបរាប់ខាងលើទាក់ទងនឹងទម្រង់ជាក់លាក់នៃការកេងប្រវ័ញ្ចដែលអាចត្រូវនឹងស្ថានភាពបន្ថែមទៅលើសញ្ញាទាំងឡាយខាងក្រោមដែលត្រូវជាមួយនឹងគ្រប់ទម្រង់នៃការកេងប្រវ័ញ្ច។

> *ការលំបាកក្នុងការសំគាល់ជាជនរងគ្រោះពីការជួញដូរដែលគេបានកេងប្រវ័ញ្ចក្នុងសកម្មភាពឧក្រិដ្ឋកម្ម*
>
> *ជនដែលគេកេងប្រវ័ញ្ចក្នុងសកម្មភាពឧក្រិដ្ឋកម្មអាចគេសំគាល់ខុសថាជាឧក្រិដ្ឋជនជាជាងជាជនរងគ្រោះពីការជួញដូរ។ ដើម្បីបន្ថយបញ្ហានេះ អាជ្ញាធរគួរមានការហាត់រៀនឲ្យបានគ្រប់គ្រាន់អំពីការប្រើ 'មធ្យោបាយ' ដោយអ្នកជួញដូរក្នុងការគ្រប់គ្រងមនុស្សហើយដាក់អ្នកនោះក្នុងស្ថានភាពកេងប្រវ័ញ្ច ហើយនិងអំពីចំណុចដែលថាការយល់ព្រមរបស់ជនរងគ្រោះឲ្យគេកេងប្រវ័ញ្ចនោះពុំមានន័យអ្វីឡើយ។*

## ការប្រើ 'មធ្យោបាយ' ដោយជនសង្ស័យថាជាអ្នកជួញដូរ

ពាក្យ 'មធ្យោបាយ' ចែងនៅក្នុងពិធីការនៃការជួញដូរមនុស្សជាសញ្ញានៃការជួញដូរ។ ទោះបីការប្រើ'មធ្យោបាយ'មិនមែនជាផ្នែកចាំបាច់ត្រូវមាននៅក្នុងបទល្មើសនៃការជួញដូរក្រោមពិធីការ the Protocol ប្រសិនបើជនរងគ្រោះជាកុមារនោះ ការប្រើវាអាចជាសញ្ញានៃការជួញដូរឬក៏ការកេងប្រវ័ញ្ចដែលពាក់ព័ន្ធ។ អាចគេប្រើមធ្យោបាយនៅដំណាក់ណាក៏បានក្នុងកម្មវិធីជួញដូរចាប់តាំងពីពេលអំពាវនាវរកមនុស្ស ដឹកជញ្ជូន ផ្ទេរ ផ្ទុក ឬទទួលមនុស្ស រហូតទៅដល់ការគ្រប់គ្រងមនុស្សនោះក្នុងដំណាក់កេងប្រវ័ញ្ច ហើយអាចប្រើវាដើម្បីឲ្យជនរងគ្រោះទទួលរងការកេងប្រវ័ញ្ចណាមួយក៏បាន។ ទោះបីការប្រើមធ្យោ បាយខ្លះគេងាយដឹង(ឧទាហរណ៍ ការប្រើកម្លាំង) ជួនកាលមធ្យោបាយមានភាពបង្កប់ហើយពិបាកសំគាល់(ឧទាហរណ៍ ការប្រើអំណាចខុស ឬឆ្លៀតឱកាសបំពានក្នុងពេលគេមានស្ថានភាពទន់ខ្សោយ)។

### ការគំរាម

- ជននោះ(ឬក្រុមគ្រួសារ មិត្តភ័ក្ត ឬសហគមន៍របស់ខ្លួន) ត្រូវបានគេគំរាម
- ជននោះ(ឬក្រុមគ្រួសារ មិត្តភ័ក្ត ឬសហគមន៍របស់ខ្លួន) ត្រូវបានគេគំរាមដោយប្រើកម្លាំង
- ជននោះត្រូវបានគេគំរាមថាស្ថានភាពរស់នៅនិងកន្លែងធ្វើការនឹងចុះអន់ថយ។
- ជននោះត្រូវបានគេគំរាមថាគេនឹងយកទៅប្រគល់ឲ្យអាជ្ញាធរ
- ជននោះត្រូវបានគេគំរាមដោយប្រើកម្លាំង

### ការប្រើកម្លាំង

- ជននោះមានសញ្ញាស្នាមរបួសផ្លូវកាយ
- ជននោះមានសញ្ញាស្នាមរបួសផ្លូវចិត្ត
- ជននោះមានសញ្ញារងការបំពានផ្លូវភេទ ឬរំលោភសេពសន្ថវៈ

### ការកៀបសង្កត់

- ជននោះមានបញ្ហាក្នុងគ្រួសារឬសេដ្ឋកិច្ច
- ជននោះមានប្រវត្តប្រព្រឹត្តល្មើសឬបើពុំដូច្នោះទេ អាជ្ញាធរស្គាល់

- ជននោះមានស្ថានភាពអន្តោប្រវេសន៍មិនប្រក្រតីនិង/ឬមិនមានឈ្មោះក្នុងបញ្ជី
- ឯកសារ ប្រាក់កាស ឬរបស់របរផ្សេងទៀតរបស់ជននោះត្រូវបានដកហូត
- ជននោះបានធ្វើកិច្ចព្រមព្រៀងខ្ចីប្រាក់ជាមួយគេដែលមិនយុត្តិធម៌
- ជននោះនៅដាច់ពីគេ ស្ថិតក្នុងបន្ទប់ឃុំឃាំង និង/ឬស្ថិតក្រោមការឃ្លាំមើលឬការត្រួតមើល
- ជំនឿសាសនានិងវប្បធម៌របស់ជននោះត្រូវបានគេកែក្រឡៃ

**ការចាប់ជម្រិត**

**ការក្លែងបន្លំ/បោកប្រាស់** (ពត៌មានក្លែងក្លាយ មិនត្រឹមត្រូវ មិនពេញលេញ ឬអាចធ្វើឲ្យគេយល់ខុស) ទាក់ទងទៅនឹង :

- កិច្ចការទេសន្តរប្រវេសន៍ឬការរំពឹងទុករបស់ជននោះ (រួមទាំងទីដៅ)
- ស្ថានភាពនៃការធ្វើដំណើរនិងការស្វែងរកការងាររបស់ជននោះ
- ស្ថានភាពការងាររបស់ជននោះ រួមទាំងប្រភេទការងារ បៀវត្ត និង ប្រាក់ចំណូល
- លទ្ធភាពទទួលឱកាសសិក្សារបស់ជននោះ
- ស្ថានភាពផ្ទះសម្បែង ទីតាំងនិងការរស់នៅរបស់ជននោះ
- លក្ខណៈច្បាប់នៃឯកសារ ទិដ្ឋាការ ការងារ ឬ កិច្ចសន្យារបស់ជននោះ
- ច្បាប់ ឥរិយាបទ ឬអាកប្បកិរិយារបស់អាជ្ញាធរចំពោះជននោះ។
- សេចក្តីសង្ឃឹមអំពីការជួបជុំគ្រួសារវិញ អាពាហ៍ពិពាហ៍ ឬការសុំយកទៅចិញ្ចឹម របស់ជននោះ

**ការប្រើអំណាចខុស ឬការឆ្លៀតឱកាសបំពានពេលគេស្ថិតក្នុងស្ថានភាពទន់ខ្សោយ 37 តាមរយៈការធ្វើខុសនៅពេលឬដោយសារ ៖**

- ការពឹងផ្អែកក្នុងវិស័យសេដ្ឋកិច្ច ផ្លូវចិត្ត ឬមនោសញ្ចេតនារបស់ជននោះ ទៅលើអ្នកកេងប្រវ័ញ្ច/ថៅហ្វាយនាយ/សមាជិកគ្រួសារ ឬ នាក់ទំនងរបស់ជននោះជាមួយអ្នកកេងប្រវ័ញ្ច/ថៅហ្វាយនាយ/សមាជិកគ្រួសារ។
- ចំណងស្នេហាឬមនោសញ្ចេតនារបស់ជននោះជាមួយអ្នកកេងប្រវ័ញ្ច/ថៅហ្វាយនាយ/សមាជិកគ្រួសារ/អ្នកណាផ្សេងទៀត
- ឯកសារនិង/ឬស្ថានភាពអន្តោប្រវេសន៍របស់ជននោះ
- ភាពដាច់ឯកោក្នុងវិស័យសង្គម វប្បធម៌ឬភាសារបស់ជននោះ
- ភាពគ្មានការងារធ្វើ ឬអត្តខាត់ថវិការបស់ជននោះ
- ភាពពិការផ្លូវចិត្តឬផ្លូវកាយរបស់ជននោះ
- អាយុ(ក្មេងឬចាស់) ភេទ ទំនោរវិស័យភេទ សញ្ជាតិ ជាតិសាសន៍ឬសង្គមដើម និងភាពពិការរបស់ជននោះ
- ជំនឿ ឬទម្លាប់ ក្នុងវិស័យសាសនាឬវប្បធម៌ របស់ជននោះ
- ការពឹងផ្អែកលើគ្រឿងញៀនឬសុរា ឬភាពញៀនរបស់ជននោះ

**ការឲ្យឬទទួលប្រាក់ឬផលប្រយោជន៍ដើម្បីទទួលបាននូវការឯកភាពពីជនម្នាក់ដើម្បីគ្រប់គ្រងលើជនម្នាក់ទៀត :**

- ជននោះស្ថិតក្នុងស្ថានភាពដែលត្រូវបង់ប្រាក់ ជំនួនអាពាហ៍ពិពាហ៍ ឬឲ្យឬទទួលអំណោយទៅជនទី៣

37 ចូរមើល ការធ្វើអំពើទុច្ចរិតពេលគេស្ថិតក្នុងស្ថានភាពទន់ខ្សោយនិងមធ្យោបាយផ្សេងៗទៀតក្នុងនិយមន័យនៃការជួញដូរមនុស្ស UNODC ឆ្នាំ២០១២ (Abuse of a Position of Vulnerability and other "means" within the definition of trafficking in persons, UNODC, 2012 ) និងកំណត់ចំណាំណែនាំស្តីអំពី ការធ្វើអំពើទុច្ចរិតពេលគេស្ថិតក្នុងស្ថានភាពទន់ខ្សោយដើម្បីជាមធ្យោបាយក្នុងការជួញដូរមនុស្ស (Guidance Note on 'abuse of a position of vulnerability' as a means of trafficking in persons) ក្នុងប្រការ៣ នៃពិធីការដើម្បីទប់ស្កាត់ សង្កត់ និងដាក់ទណ្ឌកម្ម ការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ (the Protocol to Prevent, Suppress and Punish Trafficking in Persons, Especially Women and Children), បន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនរៀបចំ UNODC ឆ្នាំ២០១២ (the United Nations Convention against Transnational Organized Crime, UNODC, 2012.

## របៀបដែលជនសន្មតថារងគ្រោះធ្វើដំណើរទៅ ចូល ឬបន្តនៅរដ្ឋបរទេសមួយ

ក្នុងស្ថានភាពដែលជនម្នាក់ត្រូវបានសង្ស័យថាជាជនរងគ្រោះពីការជួញដូរឆ្លងដែន របៀបដែលជននោះធ្វើដំណើរទៅ ចូល ឬបន្តនៅរដ្ឋបរទេសមួយអាចបង្ហាញឲ្យឃើញស្ថានភាពថាជាជនរងគ្រោះពីការជួញដូរ :

- ឯកសារធ្វើដំណើរឬអត្តសញ្ញាណប័ណ្ណរបស់ជននោះកាន់/បង្ហាញដោយភាគីទី៣
- ភ្នាក់ងាររកការងារឲ្យធ្វើ និង/ឬភ្នាក់ងារលក់សំបុត្រសម្រាប់ការធ្វើដំណើរ គ្មានចុះបញ្ជី និង/ឬមិនស្ថិតក្នុងការគ្រប់គ្រងដោយច្បាប់ និង/ឬគិតថ្លៃសេវាខ្ពស់ពីជននោះ
- ទិដ្ឋាការប្រើមិនត្រូវ និង/ឬគោលបំណងនៃការធ្វើដំណើរមិនស៊ីគ្នាជាមួយព័ត៌មានដទៃ (ឧទាហរណ៍ ប្រាក់មិនគ្រប់គ្រាន់សម្រាប់ប្រវែងស្នាក់នៅ លក្ខណៈផ្លូវកាយរបស់ជនធ្វើដំណើរ ឬអាជីពដែលបានប្រកាស)
- ឥវ៉ាន់របស់ជននោះមិនស៊ីគ្នាជាមួយនឹងពាក្យថ្លែងរបស់ជននោះ (ឧទាហរណ៍ គុណភាពនិងប្រភេទរបស់ឥវ៉ាន់ វ៉ាលីតូចសម្រាប់ការស្នាក់នៅដែលត្រូវនៅយូរ ឬក៏វ៉ាលីធំសម្រាប់ការស្នាក់នៅដែលត្រូវនៅខ្លី)
- ជននោះធ្វើដំណើរក្នុងក្រុមមនុស្សដែលជននោះហាក់ដូចជាមិនស្គាល់
- ជននោះមានឯកសារបញ្ជាក់អត្តសញ្ញាណ ឯកសារការងារ និង/ឬឯកសារធ្វើដំណើរ ក្លែងក្លាយ និង/ឬព័ត៌មានផ្តល់ឲ្យដោយអ្នកធ្វើដំណើរទាំងនោះមិនគួរជាទីទុកចិត្ត។
- ជននោះវង្វេងវង្វាន់អំពីផ្លូវធ្វើដំណើរ ទីដៅ ឬគោលបំណងនៃការធ្វើដំណើររបស់ខ្លួន។
- ជននោះមានស្ថានភាពទិដ្ឋការមិនប្រក្រតី(រួមទាំងដោយមូលហេតុត្រូវគេដកហូតឯកសារអត្តសញ្ញាណឬការបណ្តេញចេញពីការងារ)

## លក្ខណៈផ្លូវកាយរបស់ជនសន្មតថារងគ្រោះ

ជនរងគ្រោះពីការជួញដូរជាច្រើនរងគ្រោះផ្លូវចិត្តនិងផ្លូវកាយយ៉ាងធ្ងន់ធ្ងរក្នុងពេលគេជួញដូរ។ ស្ថានភាពផ្លូវកាយរបស់ជនរងគ្រោះនៅពេលគេប្រទះឃើញ អាចឲ្យគេដឹងថាជននោះអាចជាជនរងគ្រោះឬមិនមែន។ ទោះជាយ៉ាងណា គេត្រូវចាំថាជនរងគ្រោះពីការជួញដូរជាច្រើនមិននិយាយថាខ្លួនជាជនរងគ្រោះទេ ហើយមើលហាក់ដូចជាគេពេញចិត្តនិងស្ថានភាពរបស់គេ។[38] ការនៅតែប្រកាសរបស់ជនម្នាក់ថាគេពេញចិត្តនឹងស្ថានភាពមួយអាចជាការបញ្ជាក់ថាអ្នកជួញដូរបានបង្ខិលជននោះប្រកបដោយប្រសិទ្ធិភាពប៉ុណ្ណោះ។

**ស្ថានភាពផ្លូវចិត្តនិងសញ្ញាក្នុងអាកប្បកិរិយា** :

- ជននោះហាក់ដូចជាអន្ទះអន្ទែងកើតទុក្ខចេះតែគោរពធ្វើតាមខ្លាចមានអារម្មណ៍តឹងតែងភ័យចេះតែទាស់នេះទាស់នោះ
- ជននោះបដិសេធមិនមើលភ្នែកចំ
- ជននោះរួញរាក្នុងការនិយាយឬពិគ្រោះអំពីរឿងសនានា

**សញ្ញាផ្លូវកាយនៃការដែលគេប្រព្រឹត្តមិនត្រឹមត្រូវមកលើ និង/ឬការដែលគេមិនយកចិត្តទុកដាក់** :

- ជននោះមានសញ្ញាគេប្រើហិង្សាដោយកម្លាំងមកលើ
- ជននោះមានសញ្ញានៃការញៀណ/ពឹងផ្អែក/ប្រើ គ្រឿងញៀណឬសុរា
- ជននោះមានសញ្ញាមិនមានអាហារគ្រប់គ្រាន់ ឬលក្ខណៈកាយផ្សេងទៀតដែលបណ្តាលមកពីការបង្អត់អាហារ ទឹក ដំណេក ពេទ្យមើលថែ ឬវត្ថុចាំបាច់សម្រាប់ជីវិតឯទៀតៗ។
- ជននោះមានសញ្ញាខ្វះអនាម័យដោយសារខ្វះមធ្យោបាយលាងសំអាត។

38 ចូរមើលផ្នែក ២.២.

## ស្ថានភាពកន្លែងដែលគេប្រទះឃើញជនសន្មតថារងគ្រោះស្នាក់នៅនិង/ឬធ្វើការ

សញ្ញានានាស្តីអំពីការរស់នៅនិងឬការធ្វើការមានការទាក់ទងនឹងការកេងប្រវ័ញ្ចលើជនរងគ្រោះពីការជួញដូរ។ ជនសន្មតថារងគ្រោះគេអាចឃើញមាននៅក្នុងឧស្សាហកម្មនិងបរិបទជាច្រើន រួមទាំងឧស្សាហកម្មផ្លូវភេទក៏ដូចជាការងារក្នុងផ្ទះ ការមើលក្មេង សេវាសុខាភិបាល ការមើលថែមនុស្សចាស់ កីឡា ការកំសាន្ត ការទទួលភ្ញៀវ សំណង់ ព្រៃឈើ នេសាទ រ៉ែ កសិកម្ម ហើយនិងតម្បាញ។ សញ្ញាទាំងឡាយខាងក្រោមនេះត្រូវនឹងគ្រប់បរិបទដែលជនសន្មតថារងគ្រោះរស់នៅនិង/ឬធ្វើការ។

**បៀវត្សនិងកិច្ចសន្យា:**

- ជននោះត្រូវបានហាមឃាត់មិនឲ្យផ្ញើនិង/ឬវេរប្រាក់កែប្រែនិងបាក់សន្សំ
- ជននោះទទួលបានប្រាក់កម្រៃតិចតួចឬគ្មានប្រាក់កម្រៃពីការងារ ឬប្រាក់កម្រៃត្រូវពន្យា
- ប្រាក់កម្រៃជននោះទទួលបានទាបជាងកំរិតដែលគេបានសន្យាឬកំរិតអប្បបរមារបស់ជាតិ
- គេដកប្រាក់ច្រើនហួសហេតុពីក្នុងបៀវត្សរបស់ជននោះរួមទាំងសម្រាប់បង់សងថៅហ្វាយនាយ/ភ្នាក់ងារផ្តល់ការងារ
- ជននោះត្រូវបានគេបដិសេធមិនឲ្យទទួលផលប្រយោជន៍និងការការពារសង្គមដែលគេត្រូវទទួលបានដោយស្របច្បាប់
- ជននោះពុំបានចុះហត្ថលេខាក្នុងកិច្ចសន្យាឬមាត្រាក្នុងកិច្ចសន្យាពុំមានគេគោរព។
- ជននោះត្រូវបានគេតម្រូវឲ្យចុះហត្ថលេខាកិច្ចសន្យាថ្មីនៅពេលមកដល់នោះនិង/ឬពេលចាប់ផ្តើមធ្វើការ។
- ថៅហ្វាយនាយពុំអាចបង្ហាញភស្តុតាងនៃការបង់ប្រាក់បៀវត្សឲ្យបុគ្គលិក
- ជននោះត្រូវបានគេបញ្ឈប់ពីការងារដោយគ្មានមូលហេតុ សេចក្តីជូនដំណឹង និង/ឬ ប្រាក់បំណាច់។

**សុខភាពនិងសុវត្ថិភាពនៅកន្លែងធ្វើការ:**

- គេពុំបានឲ្យជននោះនូវប្រដាប់ប្រដានិងឧបករណ៍សុវត្ថិភាពនិងសម្រាប់ការពារ ឬបង្ហាត់ឲ្យចេះប្រើឧបករណ៍និងប្រដាប់ប្រដានានា។
- ជននោះត្រូវបានគេបដិសេធមិនឲ្យទទួលសេវាពេទ្យមើលថែ
- ជននោះធ្វើការច្រើនម៉ោងហួសហេតុ/ម៉ោងចម្លែកហួសហេតុ
- ជននោះមានពេលលំហែតិចតួចឬគ្មានពេលលំហែ
- ជននោះរងការដាក់ទណ្ឌកម្ម/ពិន័យចំពោះការធ្វើពុំបានគ្រប់តាមកំណត់

**ការដាក់កំណត់ក្នុងការធ្វើចលនានិងគុណភាពសម្ភារៈទាបជាងស្តង់ដា:**

- ជននោះមានសញ្ញាថាមានការកៀបចងកាយឬឃាំងក្នុងកន្លែងធ្វើការឬកន្លែងដទៃ (ឧទាហរណ៍ បង្អួចបិទ/ដាក់ចម្រឹងទ្វារចាក់សោពីក្រៅ លួសបន្លា ម៉ាស៊ីនថតការពារសុវត្ថិភាព)
- ជននោះដេកនៅកន្លែងដែលគេនោះធ្វើការ
- ជននោះត្រូវគេបដិសេធមិនឲ្យមានលទ្ធភាពប្រាស្រ័យទាក់ទងបាន
- ជននោះពុំកាន់កាប់ឯកសារធ្វើដំណើរ/បញ្ជាក់អត្តសញ្ញាណដោយខ្លួនឯង និង/ឬឯកសារត្រូវបានដកហូតដោយថៅហ្វាយនាយរបស់ខ្លួនឬអ្នកដទៃ។ [39]

---

[39] ចំពោះពត៌មានបន្ថែមនិងប្រភពនៃសញ្ញាទ្បាយ សូមមើលតារាងធនធាន (Matrix of Resources)

# ផ្នែកទី៤ :

## ការប្រមូលផ្តុំតម្រុយសម្រាប់ការសំគាល់ជនរងគ្រោះពីការជួញដូរ

- ✓ **បញ្ចូលការសន្មតដែលធ្វើឲ្យយើងធ្វើអ្វីៗហាក់ដូចជាអ្នកដែលគេបានសន្មតថាជាជនរងគ្រោះនោះជាជនរងគ្រោះ** គោលនយោបាយរបស់រដ្ឋគួរអនុញ្ញាត្តិឲ្យអាជ្ញាធរដែលសង្ស័យថាជនម្នាក់ជាជនរងគ្រោះពីការជួញដូរចាត់វិធានការតាមការសង្ស័យនោះគឺគិតថាជននោះជាជនរងគ្រោះដើម្បីផ្តល់ជំនួយនិងការការពារដំបូង។

- ✓ **បង្កើនការយល់ដឹងអំពីឧក្រិដ្ឋកម្មទាក់ទងនឹងការជួញដូរមនុស្ស** ជនដែលគេមិនយល់ថាជាជនរងគ្រោះពីការជួញដូរ អាចជាជនរងគ្រោះពីឧក្រិដ្ឋកម្មផ្សេងទៀត ហើយត្រូវការជំនួយនិងការការពារ។ អ្នកអនុវត្តដែលទទួលបន្ទុកក្នុការសំគាល់ជនរងគ្រោះពីការជួញដូរ គួរទទួលការយល់ដឹងអំពីប្រភេទនៃឧក្រិដ្ឋកម្មពាក់ព័ន្ធទាំងឡាយហើយមានបំពាក់អ្វីៗតបតាមសេចក្តីត្រូវការបាន។

- ✓ **សំគាល់ជនរងគ្រោះពីការជួញដូរក្នុងចំណោមក្រុមដែលងាយរងគ្រោះ** មុននឹងចូលទៅដល់ដំណាក់នៃការកេងប្រវ័ញ្ច គេពិបាករកឲ្យឃើញជនរងគ្រោះពីការជួញដូរជាទីបំផុត។ រដ្ឋគួរចាត់ឲ្យមានការចែងនៅក្នុងគោលនយោបាយរបស់ខ្លួននូវមាត្រាដែលគាំទ្រអាជ្ញាធរក្នុងការស្វែងរកជនដែលគេសន្មតជារងគ្រោះក្នុងចំណោមជនដែលងាយរងគ្រោះ រួមទាំងទេសន្តរជនដែលរត់ពន្ធផង។

- ✓ **ការសំគាល់ទាសភាព** ទាសភាពមានសញ្ញាឲ្យដឹងតាមរយៈទំនាក់ទំនងរវាងអ្នកប្រព្រឹត្តនិងអ្នករងគ្រោះជាជាងតាមលក្ខណៈនៃស្ថានភាព។ អាជ្ញាធរគួរយល់ថាមនុស្សម្នាក់ដែលស្ថិតក្នុងទាសភាពអាចរស់នៅដោយស្រួល ប៉ុន្តែពុំមានអំណាចក្នុងការសម្រេចកិច្ចការសំខាន់ៗរបស់ខ្លួនឡើយ។

- ✓ **ការសំគាល់បំណុលស្ពូជ** បំណុលស្ពូជជាបញ្ហាឧស្សាហ៍មានក្នុងរង្វង់ជនរងគ្រោះពីការជួញដូរ។ បំណុលស្ពូជអាចសំគាល់បានដោយឃើញមានបំណុលដែលមិនអាចគិតដឹងចំនួនហើយមិនអាចបង់ដាច់ទោះបីធ្វើការឬផ្តល់សេវាប៉ុន្មានក៏ដោយ។ អាជ្ញាធរជាច្រើនយល់អំពីបំណុលស្ពូជក្នុងន័យទូលំទូលាយ ថាជាការផ្តល់កម្លាំងនិងសេវាដើម្បីសងបំណុលក្នុងស្ថានភាពកេងប្រវ័ញ្ច។

- ✓ **ការសំគាល់អាពាហ៍ពិពាហ៍ដោយបង្ខិតបង្ខំ** ចាប់តាំងពីអនុសញ្ញាបន្ថែមស្តីអំពីទាសភាពចូលជាធរមានមក ដែលអនុសញ្ញានោះសំគាល់តែអាពាហ៍ពិពាហ៍ដោយបង្ខិតបង្ខំទៅលើស្ត្រី គេបានទទួលស្គាល់យ៉ាងទូលំទូលាយថាកុមារនិងបុរសពេញវ័យក៏អាចគេបង្ខំឲ្យរៀបការដែរ។ ដើម្បីប្រយុទ្ធប្រឆាំងគ្រប់ទ្រង់ទ្រាយនៃអាពាហ៍ពិពាហ៍ដោយបង្ខិតបង្ខំ គួរធ្វើច្បាប់ហាមការរៀបការដោយបង្ខិតបង្ខំយ៉ាងណាដែលអាចអនុវត្តបានស្មើភាពគ្នាដោយមិនគិតអំពីភេទរបស់ជនរងគ្រោះ។

- **ផ្តល់សញ្ញាអំពីទម្រង់ទាំងឡាយនៃការកេងប្រវ័ញ្ច** រដ្ឋទាំងឡាយគួរពិចារណាផ្តល់ដល់អាជ្ញាធរនានានូវសញ្ញានៃការជួញដូរឲ្យលំអិតនិងចំៗដើម្បីឲ្យអ្នកឆ្លើយជាលើកទីមួយ ស្គាល់ទម្រង់ទាំងឡាយនៃការកេងប្រវ័ញ្ច។ ក្នុងពេលផ្តល់ជំនួយនិងការការពារ ភស្តុតាងសម្រាប់ចំណុចផ្សេងៗទៀតដែលមានចែងក្នុងនិយមន័យអាចឃើញកាន់តែច្បាស់។ ផ្នែក3.3 ផ្តល់មូលដ្ឋានសម្រាប់បង្កើតសញ្ញាដែលមានន័យចំៗនិងលំអិត។

- **លើកទឹកចិត្តជនរងគ្រោះឲ្យចេញមកដោយដោះស្រាយបារម្ភរបស់គេអំពីរឿងឃុំឃាំងនិងរឿងបណ្តេញចេញពីប្រទេស** ដើម្បីដោះស្រាយការភ័យខ្លាចរបស់ជនរងគ្រោះអំពីការឃុំឃាំង ត្រូវបង្កើតកម្មវិធីដែលធានាជនរងគ្រោះថាគ្មានទោសពៃទេចំពោះអំពើដែលខ្លួនបានធ្វើដោយសារត្រូវបានគេជួញដូររួមទាំងបទល្មើសអន្តោប្រវេសន៍។ ដើម្បីដោះស្រាយការភ័យខ្លាចអំពីការបណ្តេញចេញពីប្រទេស គួរដាក់ឲ្យមានទិដ្ឋាការដែលអនុញ្ញាតិជនរងគ្រោះពីការជួញដូរស្ថិតក្នុងប្រទេសទីដៅដើម្បីទទួលជំនួយនិងការការពារ។

- **លើកទឹកចិត្តជនរងគ្រោះ**ឲ្យចេញមកដោយការពារគេនិងក្រុមគ្រួសារគេ រដ្ឋគួរពិចារណាបង្កើតកម្មវិធីផ្តល់ការការពារប្រកបដោយប្រសិទ្ធិភាពដល់ជនរងគ្រោះ សាក្សី និងក្រុមគ្រួសាររបស់គេ។ បើមនុស្សដែលត្រូវការការពារស្ថិតនៅរដ្ឋផ្សេង ត្រូវរកការសហការជាមួយអ្នកធ្វើកិច្ចការរកយុត្តិធម៌ក្នុងបទឧក្រិដ្ឋក្នុងរដ្ឋនោះ ឬមួយក៏បើសមស្រប ផ្តល់ទិដ្ឋាការនិងផ្លូវអន្តោប្រវេសន៍ដើម្បីផ្តល់ការការពារដល់ជនដែលអាចមានគ្រោះថ្នាក់។

- **លើកទឹកចិត្តជនរងគ្រោះឲ្យចេញមកដោយការពារមិនឲ្យមានឈ្មោះអាស្រូវ**
រដ្ឋគួរធ្វើយ៉ាងណាឲ្យជំនួយនិងការការពារមានគិតគូរអំពីការខ្លាចរបស់ជនរងគ្រោះចំពោះភាពអាមាសនិងឈ្មោះ អាស្រូវដោយរក្សាភាពសម្ងាត់របស់ពត៌មានរបស់ជនរងគ្រោះ
និងដោយធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាល សហគមន៍និងជនរងគ្រោះផ្ទាល់ដើម្បីយល់និងដោះស្រាយបារម្ភនានា ក្នុងការបង្កើតគោលនយោបាយការពារ។

- **បង្កើនការយល់ដឹងរបស់សាធារណជនអំពីការជួញដូរមនុស្សដើម្បីបង្កើនការសំគាល់ជនរងគ្រោះ** រដ្ឋនានាគួរបង្កើតនិងគាំទ្រកម្មវិធីបង្កើនការយល់ដឹងរបស់សាធារណជនអំពីស្ថានភាពនៃការជួញដូរមនុស្ស។ ជាការល្អបំផុតបើកម្មវិធីនោះពន្យល់ចំមនុស្សដែលយើងសំដៅអំពី ៖
ក អ្វីទៅជាការជួញដូរមនុស្ស និងតើវាអាចមានរូបរាងដូចម្តេច។
ខ សកម្មភាពជាក់លាក់ដែលមនុស្សម្នាក់ៗអាចធ្វើ ជាពិសេសទាក់ទងនឹងការផ្តល់ពត៌មានដើម្បីបញ្ជូនទៅអាជ្ញាធរពាក់ព័ន្ធរួមទាំងពត៌មានតាមទូរស័ព្ទរហ័ស។

- **បង្កើនសមត្ថភាពភ្នាក់ងារទាំងឡាយដែលមានតួនាទីសំគាល់** បង្កើតសេចក្តីណែនាំច្បាស់ៗនិងវិធីអនុវត្តដើម្បីពន្យល់តួនាទីនិងភារកិច្ចរបស់អាជ្ញាធរទាំងឡាយនិងអ្នកអនុវត្តពាក់ព័ន្ធឯទៀតៗ ក្នុងវិធីសំគាល់ជនរងគ្រោះដែលមានប្រសិទ្ធិភាព។

✓ **ពង្រឹងការសំគាល់កុមាររងគ្រោះពីការជួញដូរ** អនុវត្តវិធីដែលបញ្ជាក់បានឆាប់ជាមួយកុមារដែលអាចជាកុមាររងគ្រោះពីការជួញដូរ ហើយនិងផ្តល់ដំណឹងភ្លាមទៅអ្នកផ្តល់សេវាជំនាញសម្រាប់កុមារ តាមរយៈវិធីសំគាល់ដែលទទួលចំណុចទាំង២ខាងក្រោមនេះបាន ៖

- ការសន្មតថាជាកុមារ និង
- ការសន្មតថាជាជនរងគ្រោះ

✓ **គាំទ្របច្ចេកទេសសម្ភាសដែលសមស្របតាមលក្ខណៈសម្បត្តិរបស់ជនរងគ្រោះ** ធ្វើយ៉ាងណាឲ្យអ្នកសម្ភាសមានជំនាញទប់ទល់នឹងបញ្ហាក្នុងវិស័យភាសា ភេទ អាយុ និងវប្បធម៌។ តាមដែលអាចធ្វើបាន ពិគ្រោះជាមួយអ្នកដែលត្រូវគេសម្ភាសនិមួយៗអំពីអ្វីដែលគេប្រាថ្នា ហើយបំពេញបំណងគេតាមសមស្រប។

✓ **ចាត់ឲ្យកម្មវិធីសំគាល់មានលទ្ធភាពបញ្ជូនឈ្មោះរបស់ជនសុំសិទ្ធិជ្រកកោនទៅអង្គភាពនានាសមស្រប** រដ្ឋទាំងឡាយមិនគួរទាក់ទងភ្នាក់ងារស្ថានទូតរបស់ប្រទេសដើមដើម្បីធ្វើការសំគាល់ឡើយ បើជនម្នាក់បានដាក់ពាក្យសុំសិទ្ធិជ្រកកោន ឬក៏បើមានហេតុផលថាជននោះជាជនភៀសខ្លួន។

✓ **ពិចារណាដាក់កំរិតទម្ងន់ឲ្យសញ្ញា** រដ្ឋនានាគួរពិចារណាដាក់ទម្ងន់ឲ្យសញ្ញាដើម្បីជួយដល់អ្នកទទួលបន្ទុកក្នុងការសំគាល់ជនរងគ្រោះដើម្បីឲ្យពត៌មានប្រភេទខ្លះស្ថិតតាមលំដាប់លេខរៀង។ វិធីដែល ILO និងស្នងការអឺរ៉ុបប្រកាន់យក ធ្វើឲ្យសញ្ញានិមួយៗមានទម្ងន់ធ្ងន់ មធ្យមឬស្រាល ដោយមានចែងថាសញ្ញាមួយអាចធ្ងន់សម្រាប់កុមារតែមធ្យមសម្រាប់មនុស្សពេញវ័យ ឬក៏ធ្ងន់សម្រាប់ការកេងប្រវ័ញ្ចផ្លូវភេទ ហើយស្រាលសម្រាប់ការកេងប្រវ័ញ្ចពលកម្ម។

✓ **កែសម្រួលសញ្ញាទៅតាមបរិបទ** តារាងសញ្ញាមានប្រសិទ្ធិភាពបំផុតបើគេយកទៅកែប្រើក្នុងស្ថានភាពជាក់ស្តែងដែលអាជ្ញាធរពើបប្រទះក្នុងការងាររបស់ខ្លួន។ បើអាចធ្វើបាន រដ្ឋទាំងឡាយគួរពិនិត្យសើរើតារាងសញ្ញាជាប្រចាំធ្វើឲ្យទាន់សម័យ ដើម្បីធានាឲ្យត្រូវតាមទំនោរនៃការជួញដូរដែលផ្លាស់ប្តូរ។




Regional Support Office
THE BALI PROCESS

ទំនាក់ទំនង

Regional Support Office - The Bali Process
27th Floor Rajanakarn Building
3 South Sathorn Road, Sathorn Bangkok 10120, THAILAND
ទូរស័ព្ទ +66 2 343 9477 ទូរសារ +66 2 676 7337
info@rso.baliprocess.net

The Bali **Process**

on People Smuggling, Trafficking in Persons and Related Transnational Crime

http://www.baliprocess.net/